**TKI0762**

**សម្ភាសន៍ជាមួយឈ្មោះ កែវ អ៊ូច ភេទប្រុស អាយុ៥១ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ទាហាន**

**សព្វថ្ងៃរស់នៅភូមិហានទា ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ**

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សេង គន្ធី និង គីមស្រួយ សុខវិសាល**

**០១:១៥:៤៥**

**៥៧ទំព័រ**

គន្ធី : ថ្ងៃនេះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ។

វិសាល : ជំរាបសួរអ៊ំថ្ងៃនេះពួកខ្ញុំពីរនាក់នេះ គឺខ្ញុំឈ្មោះ គីមស្រួយ សុខវិសាល ជាបុគ្គលិកក្នុងគម្រោងជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយខាងនេះ ជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរគាត់ឈ្មោះ សេង គន្ធី ។

អ៊ូច : បាទ!

វិសាល : ហើយចុះមកភូមិអ៊ំថ្ងៃនេះគឺចង់មកសួរប្រវត្តិអ៊ំណាអ៊ំណា បាទៗ ។

អ៊ូច : អ៊ឺ!

វិសាល : ទាក់ទងនឹងសម័យ

អ៊ូច : ប៉ុល ពត?

វិសាល : ខ្មែរក្រហម តើធ្វើអីដែរហើយផ្លាស់ពីកន្លែងណាទៅកន្លែងណា ហើយជីវិតនៅសម័យហ្នឹងវាយ៉ាងម៉េចដែរអីអញ្ចឹងដែរណាអ៊ំណា ។ ចង់សុំអ៊ំសម្ភាសន៍អញ្ចឹងអ៊ំអនុញ្ញាតិទេអ៊ំ?

អ៊ូច : អនុញ្ញាតិហើយអត់មានបញ្ហាអីទេ ។

វិសាល : បាទៗ! ហើយចង់សុំនេះដែរចង់សុំសាច់រឿងអ៊ំ តើអ៊ំនឹងអនុញ្ញាតិឲ្យពួកខ្ញុំហ្នឹងយកសាច់រឿងរបស់អ៊ំដែលអ៊ំនិងមានប្រសាសន៍បន្តិចទៀតនេះ អាចឲ្យខ្ញុំសរសេរយកទៅប្រើប្រាស់ឧទាហរណ៍ដូចជាយកទៅសរសេរជាអត្ថបទនៅក្នុងទស្សនាវដ្តីអីបានទេ?

អ៊ូច : បាន ។

វិសាល : បាទ អត់អីទេអ៊ំណែ?

អ៊ូច : បាទ!

វិសាល : ទុកជាឯកសារប្រវត្តិសាស្ត្រគឺបាន បាទ អញ្ចឹងខ្ញុំសូមចាប់ផ្តើមសួរអ៊ំតែម្តងណាអ៊ំណា?

អ៊ូច ៖ បាទ!

វិសាល ៖ ចង់ជំរាបសួរអ៊ំ តើអ៊ំឈ្មោះអីទៅអ៊ំឈ្មោះពេញ?

អ៊ូច ៖ ឈ្មោះពេញ កែវ អ៊ូច ហ្នឹងហើយ ។

វិសាល ៖ កែវ អ៊ូច អ៊ំមានឈ្មោះហៅក្រៅទេ?

អ៊ូច ៖ ធម្មតាឈ្មោះតែមួយទេ ។

វិសាល ៖ ឈ្មោះតែមួយហ្នឹងទេ បាទ ហើយសព្វថ្ងៃអ៊ំមានអាយុប៉ុន្មានហើយអ៊ំ?

អ៊ូច ៖ ៥១ឆ្នាំ ។

វិសាល ៖ ៥១ឆ្នាំហើយអ៊ំអាចចាំថា សូមទោសអ៊ំបើអាចចាំបានអ៊ំអាចចាំបានថា អ៊ំកើតនៅថ្ងៃខែឆ្នាំណាទេ?

អ៊ូច ៖ កើតនៅមើលឆ្នាំ ហាប៉ុន្មានទេកាលហ្នឹង?

វិសាល ៖ អូ! អត់ចាំទេអ៊ីណែ គ្រាន់តែដឹងថាអាយុហាជាង ។

អ៊ូច ៖ ៥១ ។

វិសាល ៖ ៥១ បាទ អរគុណច្រើន សព្វថ្ងៃអ៊ំរស់នៅក្នុងភូមិ ឃុំ អីដែរអ៊ំ?

អ៊ូច ៖ នៅភូមិហាន់ទា ។

វិសាល ៖ ហាន់ទា ឃុំ?

អ៊ូច ៖ ឃុំកំពែង ។

វិសាល ៖ កំពែង?

អ៊ូច ៖ ស្រុកគិរីវង់ ។

វិសាល ៖ ខេត្តតាកែវ?

អ៊ូច ៖ បាទ!

វិសាល ៖ សព្វថ្ងៃអ៊ំប្រកបរបរអីដែរទៅ?

អ៊ូច ៖ ធ្វើស្រែចំការ ។

វិសាល ៖ ធ្វើស្រែចំការ បាទ ចង់សូមសួរអ៊ំ អ៊ំមានស្រុកកំណើតនៅហ្នឹងរហូត កើតជានៅហ្នឹងឯង?

អ៊ូច ៖ កំណើតកើតនៅហ្នឹងឯង ។

វិសាល ៖ អូ!

អ៊ូច ៖ នៅភូមិហ្នឹងហ្នង ។

វិសាល ៖ នៅភូមិហ្នឹងតែម្តង ឪពុកម្តាយអ៊ំគាត់ឈ្មោះអីដែរអ៊ំ?

អ៊ូច ៖ ឪពុកឈ្មោះ កែវ ដាន ម៉ែ បែន យ៉េន។

វិសាល ៖ លោកតានៅទេ ឥលូវ?

អ៊ូច ៖ ស្លាប់អស់។

វិសាល ៖ ស្លាប់ហើយ គាត់ស្លាប់នៅសម័យណាដែរ?

អ៊ូច ៖ ស្លាប់នៅជំនាន់អ៊ុំ លន់ នល់។

វិសាល ៖ ស្លាប់នៅជំនាន់ លន់ នល់ ហ្នឹងដោយមូលហេតុអីទៅ?

អ៊ូច ៖ អ៊ុំ ដោយសារគ្រោះថ្នាក់ ដោយសារខ្លួនឯងស្លាប់ដោយគ្រាប់បែក។

វិសាល ៖ អូ! មិនមែនអាមេរិចកាំងទម្លាក់គ្រាប់នោះទេ ឬមួយក៏យ៉ាងម៉េចដែរ?

អ៊ូច ៖ អត់ទេ ខ្លួនគាត់ទៅធ្វើជីវកម្ម។

វិសាល ៖ អូ!

អ៊ូច ៖ សិប្បកម្ម។

វិសាល ៖ សិប្បកម្ម?

អ៊ូច ៖ ហ្នឹងហើយ ប៉ះអាគ្រាប់វាអត់ទាន់ផ្ទុះ វានៅហ្នឹងដល់ហើយផ្ទុះខ្លួនឯង។

វិសាល ៖ ផ្ទុះស្លាប់ទាំងពីរនាក់?

អ៊ូច ៖ អត់ទេម្តាយនៅ ម្តាយស្លាប់កាលអ៊ុំ ចុះមក៧៩។

វិសាល ៖ បែក៧៩ហើយ?

អ៊ូច ៖ បែក៧៩ហើយមកស្លាប់នៅផ្ទះ។

វិសាល ៖ បាទៗ! មានបងប្អូនប៉ុន្មាននាក់ដែរលោកអ៊ំ ហើយលោកអ៊ំជាកូនទីប៉ុន្មានដែរ?

អ៊ូច ៖ បងប្អូនប្រាំមួយប្រាំនាក់ខ្ញុំទីបួន។

វិសាល ៖ បងប្អូនប្រាំមួយនាក់?

អ៊ូច ៖ ប្រាមមួយនាក់!

វិសាល ៖ ហើយលោកអ៊ំជាកូនទីបួន?

អ៊ូច ៖ ទីបួន។

វិសាល ៖ បាទ! សព្វថ្ងៃនៅជុំ នៅរស់ទាំងអស់គ្នា ឬក៏?

អ៊ូច ៖ នៅរស់ទាំងអស់។

វិសាល ៖ អូ បាទៗ ធំដឹងក្តីឡើងឪពុក លោកតាលោកយាយប្រកបរបរអីដែរពេលអ៊ំដឹងក្តីហ្នឹង?

អ៊ូច ៖ ធ្វើស្រែចំការដូចគ្នា ។

វិសាល ៖ ស្រែចំការដូចគ្នា បាទៗ ហើយកាលហ្នឹងកាលពេលនេះហ្នឹងមានបានទៅរៀនទៅសូត្រអី នឹងគេទេកាលពីនៅក្មេងណា?

អ៊ូច ៖ រៀន ។

វិសាល ៖ នៅចាំបានទេអ៊ំរៀនយ៉ាងម៉េចខ្លះ?

អ៊ូច ៖ រៀនទីដប់ រៀនថ្នាក់ទីដប់ត្រូវបង្កើតរដ្ឋប្រហារ ។

វិសាល ៖ អូ!

អ៊ំស្រី ៖ ទីដប់ពីដើមមិនមែនទីដប់ឥលូវទេ ។

អ៊ូច ៖ ទីដប់ពីដើម ។

វិសាល ៖ បងប្អូនទាំងអស់ហ្នឹងមានបានទៅរៀនទាំងអស់ទេលោកអ៊ំ?

អ៊ូច ៖ បានសិក្សាទាំងអស់ ។

វិសាល ៖ ទាំងអស់គ្នា តែដល់ពេល?

អ៊ូច ៖ ដល់រដ្ឋប្រហារឈប់ ។

វិសាល ៖ កាលហ្នឹងមូលហេតុអីទៅបានឈប់រៀនហ្នឹង?

អ៊ូច ៖ ប្រទេសច្បាំងកើតសង្គ្រាម ។

វិសាល ៖ អូ! កាលហ្នឹងសាលាគេបិទហ្មងអ៊ំណែ?

អ៊ូច ៖ សាលាបិទអត់មានគ្រូមានអីទេ ។

វិសាល ៖ បាទៗ! សាលាគេបិទតែម្តង អញ្ចឹងកូនសិស្សក្នុងភូមិហ្នឹងទាំងអ៊ំទាំងគេអត់ទៅរៀនទេ?

អ៊ូច ៖ អត់ទៅទាំងអស់សាលា ។

វិសាល ៖ នៅផ្ទះ?

អ៊ូច ៖ នៅផ្ទះទាំងអស់ ។

អ៊ំស្រី ៖ ទៅរៀនទៅអីឯណាបើស្រុកច្បាំងរកតែរត់ ។

វិសាល ៖ បាទ! អញ្ចឹងចន្លោះពីចាប់ពី៧០មកមានរឿងហេតុអីកើតឡើងចំពោះអ៊ំទៅអ៊ំ រហូតដល់ ៧០ដល់៧៥ ក៏ដូចជាគ្រួសារអ៊ំ?

អ៊ូច ៖ អាហ្នឹងគ្រួសាររបស់កនខ្ញុំដែលអ៊ី ប៉ុល ពត ចូលដល់កន្លែងសង្គ្រាមគេហៅសត្តមលន់ នល់ អញ្ចឹងហើយណា?

វិសាល ៖ បាទ!

អ៊ូច ៖ ដែនអ៊ី ដល់ហើយអញ្ចឹងដែនអ៊ីមាន ប៉ុល ពត មានអី កាលហ្នឹងក៏មិនទាន់មាន ប៉ុល ពត ដែរ លន់ នល់ ធ្វើសង្គ្រាមជាមួយខ្មែរ ខ្មែរក្រហមណា ។

វិសាល ៖ បាទ!

អ៊ូច ៖ ដល់ហើយកៀរទៅលើ ។

វិសាល ៖ កៀរទៅលើ?

អ៊ូច ៖ កៀរទៅលើដើរស្នាក់តាមភូមិតាមអីគេទៅ តាមហ្នឹងដល់ហើយធ្លាយទៅដល់ស្រុកអន្លង់វែង ស្រុកអន្គរជ័យ ។

វិសាល ៖ ចន្លោះពី៧០ដល់៧៥ហ្នឹងអ៊ំ?

អ៊ូច ៖ ហ្នឹងហើយ ។

វិសាល ៖ កាលហ្នឹងអាចចាំបានទេ នៅឆ្នាំណាដែរគេកៀរទៅហើយខាងណាដែរដែលកៀរទៅហ្នឹងអ៊ំ?

អ៊ូច ៖ អ៊ឺ! ពួកខ្មែរក្រហម ។

វិសាល ៖ អូ ឆ្នាំណាទៅ?

អ៊ូច ៖ ៧៣-៧៤ ។

វិសាល ៖ ប្រហែលជា៧៣-៧៤?

អ៊ូច ៖ ហ្នឹងហើយ ។

វិសាល ៖ គឺគេមកកៀរភូមិតែម្តង?

អ៊ូច ៖ បាទ!

វិសាល ៖ កាលហ្នឹង?

អ៊ូច ៖ គេខ្លាចទាហាន វៀតគី ។

វិសាល ៖ អូ បាទ ។

អ៊ូច ៖ ព្រោះយួនសង្គ្រាមជាមួយទាហានវៀតគីផង ។

វិសាល ៖ បាទៗ!

អ៊ូច ៖ លន់ នល់ ។

វិសាល ៖ បាទៗ លន់ នល់ អញ្ចឹងកងទ័ពខ្មែរក្រហម?

អ៊ូច ៖ បាទ!

វិសាល ៖ មកកៀរមួយភូមិទៅ?

អ៊ូច ៖ បាទ!

វិសាល ៖ ទៅណាវិញទៅអ៊ំ?

អ៊ួច ៖ ឡើងទៅស្រុកអន្លង់វែង ទាំងអស់មួយស្រុកគិរីវង្ស ។

វិសាល ៖ អូ មួយស្រុកគិរីវង្ស?

អ៊ួច ៖ បាទ! គេឲ្យទៅទាំងអស់គេឲ្យឡើងទៅលើ ។

វិសាល ៖ គេឲ្យទៅខាងគេអ៊ីណែ?

អ៊ួច ៖ គេឲ្យទៅទាំងអស់ដេញឲ្យទៅចេះតែដេញឲ្យទៅកុំឲ្យនៅ ។

អ៊ំ ៖ គេឲ្យទៅទាំងអស់មួយស្រុកមួយខេត្តតាកែវហ្នឹងនិយាយរួម ។

វិសាល ៖ បាទ! ឡើងទៅខាងភ្នំ?

អ៊ួច ៖ ឡើងទៅម្តុំស្រុកអន្លង់វែង ។

វិសាល ៖ អន្លង់វែង?

អ៊ួច ៖ ឡើងទៅនៅផ្ទះគេ ។

វិសាល ៖ បាទ!

អ៊ួច ៖ នៅតាទីហ្នឹងហើយស្រុកអន្លង់វែងហ្នឹង ។

វិសាល ៖ អូ!

អ៊ួច ៖ នៅស្តុកនៅអី ។

វិសាល ៖ អញ្ចឹងទៅម៉ាទាំងអស់គ្នាទៅ?

អ៊ួច ៖ មួយស្រុកហ្នឹងទៅទាំងអស់ ។

វិសាល ៖ ហើយស្គាល់អ្នកដែលមកគេឲ្យទៅហ្នឹងទេ?

អ៊ួច ៖ អត់ស្គាល់ទេ ។

វិសាល ៖ អត់ស្គាល់ទេ អ្នកតាកែវដូចគ្នា ឬក៏អ្នកមកពីខាងណាវិញ?

អ៊ួច ៖ អត់ដឹងទេយើងអត់ស្គាល់គេដេញមក យើងចេះតែរត់គ្នាមក ។

វិសាល ៖ តែពួកគាត់ហ្នឹងគឺកងទ័ពខ្មែរក្រហមទេ?

អ៊ួច ៖ ខ្មែរក្រហម ។

វិសាល ៖ បាទៗ! ដល់ពេលគេឲ្យទៅនៅប៉ុន្មាន រហូតដល់ប៉ុន្មានទៅ ឬក៏នៅរហូតទាល់តែដាច់ភ្នំពេញ ហ្នឹងបានមកវិញ?

អ៊ួច ៖ ដល់៧៥ ។

វិសាល ៖ អញ្ចឹងនៅហ្នឹងប្រហែលមួយឆ្នាំ?

អ៊ូច ៖ នៅជាប់ជិត អ៊ីនៅប្រហែលមួយឆ្នាំហ្នឹងហើយ ព្រោះខែទៅហ្នឹងចោលស្រូវចោលផ្ទះចោលសម្បែងអស់ ។

វិសាល ៖ ទាំងអស់គ្នា?

អ៊ូច ៖ ទាំងអស់គ្នាហ្នឹងទូទៅហ្នង ។

វិសាល ៖ បាទៗ! នៅហ្នឹងគេឲ្យធ្វើអីទៅមួយឆ្នាំហ្នឹង?

អ៊ូច ៖ អត់ធ្វើអីទេ សូមជីគេនៅអញ្ចឹងទៅជួយធ្វើស្រែធ្វើចំការគេអញ្ចឹងទៅ នៅកាលហ្នឹងអាខ្លះនៅក្រោមដើមឈើអញ្ចឹងទៅ ។

វិសាល ៖ បាទ ហើយដល់អញ្ចឹងទៅដល់ពេលនៅហ្នឹងទៅ មានខាងគេអាមេរិចការងារអីទម្លាក់គ្រាប់បែកអីទេ ឬក៏លែងមានហើយ?

អ៊ូច ៖ ម្ដុំហ្នឹងអត់មានទេ គេទម្លាក់លើភ្នំ ។

វិសាល ៖ លើភ្នំ?

អ៊ូច ៖ លើភ្នំ ។

វិសាល ៖ កាលហ្នឹងខាង លន់ នល់ អីណែ?

អ៊ូច ៖ ហ្នឹងហើយខាង លន់ នល់ ។

វិសាល ៖ បាទៗ ហើយនៅហ្នឹងមានទាហានច្រើនទេអ៊ំ នៅកន្លែងភូមិដែលគេកៀរអ៊ំទៅនៅ?

អ៊ូច ៖ អត់ដែលឃើញ ដែលតែពុតែគេតិចវៃគ្នានៅនោះតិចវៃគ្នានៅនេះ ។

វិសាល ៖ អញ្ចឹងមុនដំបូងទាហានមកកៀរអ៊ំពី បងប្អូនប្រជាជនពីកន្លែងនេះទៅដាក់កន្លែងហ្នុងគ្រាន់តែទុកចោលទេ?

អ៊ូច ៖ អ៊ឺ គ្រាន់តែរំដោះៗទៅទេ ។

វិសាល ៖ គ្រាន់តែរំដោះទេ?

អ៊ូច ៖ បាទ!

វិសាល ៖ អញ្ចឹងគេអត់យាមអត់ឲ្យយើងរត់ទៅណាអត់ទេ?

អ៊ូច ៖ អត់ៗទេ ។

វិសាល ៖ ហើយអត់មានអ្នករត់ចេញមកវិញទេកាលហ្នឹង?

អ៊ូច ៖ អត់មានទេទាំងអស់គ្នាខ្លាច ។

វិសាល ៖ អូ!

អ៊ូច ៖ សូម្បីតែក្នុងភូមិក៏ទម្លាក់គ្រាប់បែកដែរមួយដួរហ្នឹងអីនេះ ។

វិសាល ៖ អញ្ចឹង៧៣-៧៤ កំពុងពេញដៃទម្លាក់គ្រាប់បែកហើយ?

អ៊ុំច ៖ បាទ ពេញ ។

អ៊ុំស្រី ៖ ទម្លាក់ឆេះផ្ទះឆេះអីអស់ហើយ ។

អ៊ុំច ៖ ឆេះផ្ទះឆេះអីអ្នកណាឆេះផ្ទះៗអ្នកណាផ្ទះនៅៗ ។

វិសាល ៖ បាទ កាលហ្នឹងបងប្អូនលោកអ៊ុំមានផ្នែកមានគ្រួសារហើយឬនៅ ឬមួយក៏មានខ្លះហើយ?

អ៊ុំច ៖ មានខ្លះនៅខ្លះ ។

វិសាល ៖ អូ មានប៉ុន្មាននាក់ដែរ តើអាចចាំដែរទេអ៊ុំ?

អ៊ុំច ៖ មានពីរនាក់ស្រីៗ ។

វិសាល ៖ អូ ពីរនាក់ តែការហើយនៅក្នុងភូមិហ្នឹងដដែលទេ?

អ៊ុំច ៖ ហ្នឹងហើយការហើយនៅក្នុងភូមិ ។

វិសាល ៖ អូ!

អ៊ុំច ៖ នៅភូមិហានទាដែរ ។

វិសាល ៖ បាទៗ! អ៊ុំដល់ពេលនៅទីនោះប្រហែលមួយឆ្នាំណែ នៅជាមួយគេធ្វើអីឲ្យគេហូបអីជាមួយគេទៅ?

អ៊ុំច ៖ បាយឆ្នាំងអង្ករយើងត្រូវដាក់តាមអញ្ចឹងទៅ ។

វិសាល ៖ បាទ! កាលហ្នឹងដូចថាអត់មានបាយរួមសហករណ៍អីទេ?

អ៊ុំច ៖ អត់ទេ ។

វិសាល ៖ អត់ទេ?

អ៊ុំច ៖ ឆ្នាំងតូច ។

វិសាល ៖ បាទ! ឆ្នាំងអីគេដែរអ៊ុំ?

អ៊ុំច ៖ ឆ្នាំងតូចយើងដាក់ដាំហ្នឹង ។

វិសាល ៖ ឆ្នាំងតូច ។

អ៊ុំច ៖ តាមគ្រួសារណា ។

វិសាល ៖ បាទៗ! ដល់ពេលបែកភ្នំពេញបានត្រលប់មកស្រុកវិញ?

អ៊ុំច ៖ បាទ បែកភ្នំពេញបានមកស្រុកវិញ ។

វិសាល ៖ បាទ!

អ៊ុំច ៖ ផ្ទះអ្នកណាអ្នកហ្នឹងវិញ ភូមិអ្នកណាភូមិហ្នឹងវិញនាំគ្នាមកនៅវិញតាមផ្ទះ ។

វិសាល ៖ បាទ! ពេលបែកហ្នឹងពីណាគេអ្នកទៅប្រាប់ឲ្យដឹងអាចមកស្រុកវិញ?

អ៊ុំប ៖ គេបេះតែមកទាំងអស់គ្នាអញ្ជឹងហ្នង ។

វិសាល ៖ អូ!

អ៊ុំប ៖ បេះតែមកទាំងអស់គ្នាមកនឹកផ្ទះនឹកសម្បែង ។

វិសាល ៖ បាទៗ!

អ៊ុំប ៖ គេក៏មកយើងក៏មក ។

វិសាល ៖ កាលហ្នឹងមុនមកមានបានឮគេប្រកាសថា ហូ យើងបានទទួលជ័យជំនះហើយអីអញ្ជឹងរំដោះប្រទេសបានហើយអីទេ?

អ៊ុំប ៖ ឮតើ ។

វិសាល ៖ ឮដែរ?

អ៊ុំប ៖ ឮថា អូ លន់ នល់ ចាញ់ហើយដោតទង់ជ័យសហើយ ។

វិសាល ៖ ហើយក៏មកវិញមក?

អ៊ុំប ៖ ដល់មកវិញទាំងអស់គ្នា ។

វិសាល ៖ ឮហ្នឹងឮឮតាមគេ?

អ៊ុំប ៖ ឮហ្នឹងឮតាមសម្លេងហើយហ្នឹងឮតាមសម្លេងអត់ឃើញជាក់ស្តែងទេ ។

វិសាល ៖ ឮតាមវិទ្យុ ឬក៏ឮតមាត់គ្នា?

អ៊ុំប ៖ ឮតមាត់ ។

វិសាល ៖ តមាត់គ្នា ។

អ៊ុំប ៖ អត់មានវិទ្យុមានអីផងហ្នឹង ។

វិសាល ៖ បាទៗ! ហើយអបហ្នឹងក៏ត្រលប់មកក្នុងភូមិវិញមក?

អ៊ុំប ៖ ត្រលប់មកភូមិកំណើតវិញ ។

វិសាល ៖ បាទៗ! អ៊ុំអាចជួយនិយាយរៀបរាប់បន្តិចបានទេអ៊ុំតាំងពីត្រលប់មកភូមិកំណើត តាំងពី ៧៥ រហូតដល់បែកហ្នឹងណា តើមានរឿងអីកើតឡើងចំពោះអ៊ុំខ្លះទៅអ៊ុំ?

អ៊ុំប ៖ មានដែលថាសង្គមអ៊ុំ សង្គម ប៉ុល ពត ។

វិសាល ៖ បាទ!

អ៊ូច ៖ សន្តម ប៉ុល ពត ហើយដែនវ៉ារៀបចំតាមមណ្ឌលកុមារតូចអញ្ចឹងទៅណា រៀបចំមានដាំង ដែកដាំងអីធ្វើតាមសិប្បកម្មអញ្ចឹងទៅ កសិកម្មទៅធ្វើតាមបច្ចេកទេសរបស់យើងអញ្ចឹងទៅ ណា ។

វិសាល ៖ បាទ!

អ៊ូច ៖ ដូចមានយាយៗអ៊ុំៗអីត្រូវទៅកាប់ស្មឹកឈើដាក់អន្ទង់ធ្វើជីធ្វើអីអញ្ចឹងទៅ ធ្វើជីធម្មជាតិ អញ្ចឹងទៅ ។

វិសាល ៖ បាទ!

អ៊ូច ៖ ហក ស្រែហ្នឹងធ្វើជាស្រែរួមអញ្ចឹងទៅ លើកដីធ្លីមានប្រឡាយមានទំនប់ទប់អីអញ្ចឹងទៅ ។

វិសាល ៖ បាទ!

អ៊ូច ៖ ហើយកងកុមាររៀបចំតាមកុមាររៀនបណ្តើរវែកដីដឹងដូកអីបណ្តើរអញ្ចឹងទៅ ហក មិត្តនារីគេ ប្រមូលទុកម្ដុំអញ្ចឹងទៅ កម្លាំងយុវជនគេប្រមូលទុកម្ដុំអញ្ចឹងទៅ ។

វិសាល ៖ បាទ! មានអីខ្លះទៀតទៅដែលលោកអ៊ុំអាចចាំបាន?

អ៊ូច ៖ ដល់តែពេលរៀបចំមកយូហើយអញ្ចឹងទៅ ទុកចាបាយរួមម្ដង ។

វិសាល ៖ បាយរួម?

អ៊ូច ៖ មានកន្ទែងចុងភៅគេខ្លះពីរបីបួនប្រាំ ។

វិសាល ៖ ខ្លះរួមហ្នឹងឆ្នាំណាដែរទៅអ៊ុំ?

អ៊ូច ៖ ឆ្នាំដូច៧៦-៧៧ ហើយ ។

វិសាល ៖ ៧៦-៧៧?

អ៊ូច ៖ អ៊ឺ!

វិសាល ៖ បាទ អ៊ឺ អញ្ចឹងខ្ញុំសូមសួរអ៊ុំមួយដំណាក់ៗវិញណា?

អ៊ូច ៖ បាទ!

វិសាល ៖ បាទ មានស្រសាសន៍តាមដែលអ៊ុំអាចចាំបាន បើអ៊ុំអត់ចាំក៏អត់អីដែរណាអ៊ុំណា?

អ៊ូច ៖ បាទ!

វិសាល ៖ ព្រោះវាកន្លងមកសាមសិបឆ្នាំហើយ
ពេលត្រប់មកវិញហ្នឹងអ៊ុំត្រលប់មកទាំងគ្រួសារតែម្ដង?

អ៊ូច ៖ មកទាំងគ្រួសារ ។

វិសាល ៈ កាលហ្នឹងដូចជាមានបងស្រីពីរនាក់រៀបការរួចហើយ អញ្ចឹងគាត់អត់នៅជុំគ្នាទៀតទេ ត្រូវទេ?

អ៊ូច ៈ ខ្ញុំចែកបានចែកឆ្នាំងហើយ ។

វិសាល ៈ បាទ! អញ្ចឹងមកវិញនៅសល់ដូចជា?

អ៊ូច ៈ នៅសល់បួននាក់ ។

វិសាល ៈ នៅសល់បួននាក់កូនហើយនឹងម្ដាយម្នាក់?

អ៊ូច ៈ ហ្នឹងហើយៗ ។

វិសាល ៈ អញ្ចឹងនៅផ្ទះជុំគ្នា?

អ៊ូច ៈ បាទ!

វិសាល ៈ ផ្ទះហ្នឹងហ្មង ឬក៏?

អ៊ូច ៈ អត់ទេផ្ទះចាស់ ។

វិសាល ៈ ផ្ទះចាស់?

អ៊ូច ៈ ឆ្ងាយពីនេះប្រហែលជាមួយរយម៉ែត្រជាង ។

វិសាល ៈ បាទៗ! ពេលត្រលប់មកវិញនៅជុំគ្នាប្រាំនាក់?

អ៊ូច ៈ បាទ!

វិសាល ៈ ចង់សុំជម្រាបសួរអ៊ំកាលហ្នឹងមកវិញប្រកបរបរអីដែរអ៊ំ?

អ៊ូច ៈ ធ្វើស្រែចំការដូចគ្នា ។

វិសាល ៈ ដូចគ្នា ធ្វើស្រែហ្នឹងអញ្ចឹងកាលហ្នឹងអត់ទាន់បាយរួមទេ?

អ៊ូច ៈ អត់ទាន់ទេដល់៧៦-៧៧បានបាយរួម ។

វិសាល ៈ បានបាយរួមអញ្ចឹងយើងធ្វើស្រែបានហើយយកទុកហូបរៀងៗខ្លួនទៅ?

អ៊ូច ៈ ហ្នឹងហើយ ។

វិសាល ៈ បាទៗ! កាលហ្នឹងមានចាំឈ្មោះមេភូមិ អ្នកគ្រប់គ្រងក្នុងភូមិអ៊ំទេ?

អ៊ូច ៈ អត់ ។

វិសាល ៈ អត់ស្គាល់ ឬក៏អត់ចាំអ៊ំ?

អ៊ូច ៈ អត់ស្គាល់ព្រោះកាលហ្នឹងខ្ញុំនៅតូចដែរ ។

វិសាល ៈ អូ! បាទ តែគាត់មិនមែនអ្នកនៅក្នុងភូមិហ្នឹងទេ?

អ៊ូច ៈ មេភូមិ?

វិសាល ៖ បាទ!

អ៊ូច ៖ មេភូមិអត់ដឹងព្រោះខ្ញុំនៅកុមារតូចអត់ដឹងស្អីៗទេ។

វិសាល ៖ អូ! កាលហ្នឹងប្រហែលអាយុប៉ុន្មានដែរនៅកុមារតូចហ្នឹងអ៊ំ?

អ៊ូច ៖ អាយុនៅខ្ទង់ដប់ឆ្នាំជាង។

វិសាល ៖ ដប់ឆ្នាំជាង បាទៗ ដប់ប្រាំដប់ប្រាំមួយ ឬក៏ដប់ស្ដើងទេ?

អ៊ូច ៖ ដល់តែពេលខ្ញុំអញ្ចេះដល់តែពេល៧៦-៧៧ហ្នឹងដប់ស្ដើង ទៅដល់ពេលគេចប់អត់បាននៅស្រុកទៀត គេប្រមូលផ្ដុំជាកងផលិតទៅនៅម៉ុំអញ្ចឹងទៅ។

វិសាល ៖ បាទៗ! អញ្ចឹងនៅធ្វើស្រែចំការរហូតអញ្ចឹងទៅ?

អ៊ូច ៖ រហូតហើយប្អូនៗគេប្រមូលដាក់ម្ដុំអញ្ចឹងទៅ ហើយម្ដាយនៅចាំផ្ទះ។

វិសាល ៖ ចាំផ្ទះ?

អ៊ូច ៖ បាទ!

វិសាល ៖ អាហ្នឹង៧៥ ឬក៏ឆ្នាំណា?

អ៊ូច ៖ ៧៦-៧៧។

វិសាល ៖ ៧៦-៧៧ អញ្ចឹងពី៧៥ដល់៧៦អ៊ំធ្វើស្រែបងប្អូនអ៊ំធ្វើស្រែចម្ការ អ្នកភូមិអីធ្វើស្រែចម្ការធម្មតា?

អ៊ូច ៖ បាទ! តែខ្ញុំចេញទៅគេឲ្យចេទៅប្រមូលផ្ដុំ។

វិសាល ៖ ចេញទៅប្រមូលផ្ដុំនៅឆ្នាំណាដែរអ៊ំ?

អ៊ូច ៖ ៧៦-៧៧ហ្នឹង។

វិសាល ៖ អាចថាចុង៧៦ កណ្ដាល ឬក៏ដើម?

អ៊ូច ៖ មិនដឹងដែរហ្នឹង។

វិសាល ៖ ប្រហែល៧៦-៧៧?

អ៊ូច ៖ បាទ!

វិសាល ៖ ចេញទៅៗធ្វើអីដែរអ៊ំ?

អ៊ូច ៖ ធ្វើកងយុវជនប្រមូលផ្ដុំហៅកងផលិតៗ។

វិសាល ៖ កងផលិត?

អ៊ូច ៖ បាទ ប៉ុនៗហ្នឹងអីទៅទាំងអស់ប្រមូលទៅទាំងអស់។

វិសាល ៖ កងផលិតហ្នឹងនៅភូមិណាដែរនៅភូមិយើងនេះ?

អ៊ូច ៖ អុឺ ប្រមូលទៅនៅឯឃុំអន្លុង្ក្រប្រាសាទ ។

វិសាល ៖ ឃុំអន្លុង្ក?

អ៊ូច ៖ ប្រាសាទ ទៅនៅហ្នឹង ។

វិសាល ៖ ស្រុក អុឺ ភូមិអីដែរអ៊ំភូមិ?

អ៊ូច ៖ នៅភូមិរនាមត្នោត ។

វិសាល ៖ រនាមត្នោត កាលហ្នឹងគេប្រមូលទៅគេចុចឈ្មោះហៅទៅ ឬក៏យ៉ាងម៉េចដែរអ៊ំ?

អ៊ូច ៖ អុឺ ហៅទៅហ្នុង ។

វិសាល ៖ ពីណាគេអ្នកហៅទៅ?

អ៊ូច ៖ ហ្នឹងងាប់ហើយយ៉ាងឈ្មោះអោងៗ ។

វិសាល ៖ ឈ្មោះ អោង កាលហ្នឹងគាត់ធ្វើអីដែរ?

អ៊ូច ៖ កាលហ្នឹងប្រធានយុវជន ។

វិសាល ៖ អូ ប្រធានយុវជន?

អ៊ូច ៖ បាទ!

វិសាល ៖ កាលហ្នឹងហៅក្មេងៗដូចអ៊ំទៅ?

អ៊ូច ៖ ហៅអ្នកពេញវ័យ ។

វិសាល ៖ ពេញវ័យ?

អ៊ូច ៖ បាទ!

វិសាល ៖ ប៉ុន្មាននាក់ដែរអាចចាំបានទេអ៊ំ?

អ៊ូច ៖ អូ គ្នាច្រើនណាស់រាប់រយអ្នកនោះ ។

វិសាល ៖ ពីគ្រប់ភូមិហ្នុងអ៊ំណែ?

អ៊ូច ៖ គ្រប់ភូមិប្រមូលផ្តុំគ្រប់ភូមិ ។

វិសាល ៖ ឥលូវពីភូមិអ៊ំវិញ អាចចាំបានទេប្រហែលជាប៉ុន្មាននាក់?

អ៊ូច ៖ ភូមិនេះប្រាំ ប្រាំមួយនាក់ដែរ ។

វិសាល ៖ ប្រាំមួយនាក់ដែរ?

អ៊ូច ៖ ហ្នឹងហើយ ។

វិសាល ៖ ហើយមានអ្នកនៅរស់ទេទាំងប្រាំមួយនាក់ហ្នឹងឥលូវនេះ?

អ៊ូច ៖ នៅដែរ ។

វិសាល ៖ ឈ្មោះអីខ្លះទៅអ៊ំ?

អ៊ូច ៖ ឈ្មោះ សុខ មួយ ។

វិសាល ៖ ឈ្មោះសុខ?

អ៊ូច ៖ បាទ! ទៅដែរអញ្ចឹងកងចល័ត ។

វិសាល ៖ ហើយមានបានទៅធ្វើទាហានអីដូចអ៊ំដែរទេ?

អ៊ូច ៖ អត់ទេ ។

វិសាល ៖ អត់ទេ បាទ ហើយមានពីណាទៀតទៅ?

អ៊ូច ៖ ស្លាប់អស់ហើយក្រោពីហ្នឹងធ្វើទ័ពស្លាប់អស់ហើយ ។

អ៊ំស្រី ៖ ស្លាប់បាត់ហើយបងវាហ្នឹង ។

វិសាល ៖ អូ បងរបស់អ៊ំ?

អ៊ំស្រី ៖ បងវានេះទេនេះ ។

វិសាល ៖ បាទៗ អញ្ចឹងចុងឆ្នាំ៧៦ហ្នឹង អោង ហ្នឹងគឺយក?

អ៊ូច ៖ នៅមួយទៀត មឹងទួន នៅកងផលិតដែរ ។

វិសាល ៖ មឹងទួនបាទ!

ពូ ៖ ធ្វើអីហ្នឹង?

អ៊ូច ៖ អូ គេសម្លាសន៍រឿងប៉ុលពតបន្តិច ចង់ដឹងសង្គមប៉ុលពតម៉េចវិញ ។ ហ្នឹងនៅកងផលិតជាមួយគ្នាដែរ ។

វិសាល ៖ បាទៗ ប៉ុន្តែគាត់អត់បានចូលជាទាហានដូចអ៊ំទេ?

អ៊ូច ៖ អត់ទេគាត់ត្រលប់មកវិញ ។

វិសាល ៖ បាទៗ នៅក្នុងកងផលិតនឹងនៅក្នុងភូមិរនាមត្នោត?

អ៊ូច ៖ អ៊ឺ!

វិសាល ៖ ឃុំអន្លុប្រាសាទ ស្រុកគិរីវង្សដូចគ្នាអ៊ំណែ?

អ៊ូច ៖ ដូចគ្នា ។

វិសាល ៖ អ៊ំនៅហ្នឹងធ្វើអីខ្លះទៅអ៊ំ?

អ៊ូច ៖ ធ្វើស្រែចម្ការដូចគ្នាអ្នកដាំពោតៗអ្នកធ្វើស្រែៗ គេចាត់កម្លាំងគ្នាតាមក្រុម ។

វិសាល ៖ បាទ!

ពូ ៖ ហើយដល់ពេលអត់មានគោអូសរទេះខ្លួនឯង ។

វិសាល ៈ កាលហ្នឹងមានស្គាល់មេកងគេនៅហ្នុងទេ?

អ៊ុំច ៈ ស្គាល់ ។

វិសាល ៈ គាត់ឈ្មោះអីទៅ?

អ៊ុំច ៈ សង ។

វិសាល ៈ ឈ្មោះ សង ?

អ៊ុំច ៈ អ៊ុំ!

វិសាល ៈ គាត់ស្លាប់ ឬនៅរស់ដែរអ៊ំ?

អ៊ុំច ៈ អត់ដឹង ។

ពូ ៈ ឃើញនៅផ្សារទម្លាប់នោះ ។

អ៊ុំច ៈ អញ្ជឹង?

វិសាល ៈ គាត់សព្វថ្ងៃនៅផ្សារអីដែរអ៊ំមិញហ្នឹង?

ពូ ៈ ផ្សារទម្លាប់ ។

អ៊ុំច ៈ ខ្ញុំមិនដែលជួបទេតាំងពីនោះមក ។

វិសាល ៈ ផ្សារទម្លាប់នៅក្នុងភូមិ ឃុំ អីដែរអ៊ំ?

អ៊ុំច ៈ ឃុំជាន់ជុំ ។

វិសាល ៈ ឃុំជាន់ជុំ ភូមិ?

អ៊ុំច ៈ ភូមិជាន់ជុំហ្នឹងហ្នង ។

វិសាល ៈ ស្រុកគិរីវង្សដូចគ្នា?

អ៊ុំច ៈ ដដែល ។

វិសាល ៈ អូ បាទ! អញ្ជឹងគាត់គ្រប់គ្រង?

អ៊ុំច ៈ មួយកងហ្នឹង ។

វិសាល ៈ មួយកងហ្នឹងប៉ុន្មាននាក់មានគ្នាប៉ុន្មាន?

អ៊ុំច ៈ មួយកងហ្នឹងមួយរយនាក់ជាង ។

វិសាល ៈ អូ! គាត់គ្រប់គ្រងជាងមួយរយអ្នកហើយការគ្រប់គ្រងរបស់គាត់យ៉ាងម៉េចដែរ កាលនៅសម័យហ្នុង?

អ៊ុំច ៈ មានអីឲ្យយើងធ្វើការឲ្យតែយើងធ្វើតាមគាត់ឲ្យត្រូវទៅ ហូបបាយរួមហូបអីរួមហ្នឹងណា ប៉ុនថាដូចខ្លះត្រូវគ្រុនចាញ់គ្រុនចាញ់គ្រុនអីមានពេទ្យមានអីព្យាបាលដរេ តាមហ្នឹងទៅ ។

វិសាល ៖ ពេទ្យមានដែរ?

អ៊ូច ៖ មានដែរពេទ្យអាពតហ្នឹង ។

វិសាល ៖ ដូចថាមានអ្នកធ្វើការខុសអីអញ្ចឹងយ៉ាងម៉េចដែរ?

អ៊ូច ៖ ស្តីបន្ទោសហ្នឹងហើយ ។

វិសាល ៖ ស្តីបន្ទោស?

អ៊ូច ៖ ប៉ុនតែធ្វើតែចំពោះអ្នកខូចទេ ។

វិសាល ៖ បាទៗ អ្នកខូចគេខូចយ៉ាងម៉េចទៅអ៊ំ?

អ៊ូច ៖ ខូចដូចថាប្រើអញ្ចឹងទៅធ្វេការងារខ្ជិលប្រអូសអញ្ចឹងទៅណា ត្រូវដូចថាសេរីអញ្ចឹងណាដើរនេះដើរទៅលិចឲ្យតែកើតអញ្ចឹងទៅណា ។

វិសាល ៖ បាទៗ ហើយធ្វើម៉េចទៅ?

អ៊ូច ៖ ស្តីបន្ទោសហ្នឹងហើយ ។

វិសាល ៖ បន្ទោសដែរបាទៗ ។

អ៊ូច ៖ ប៉ុនតែធ្វើដើម្បីតែអ្នកខូចទេអ្នកអត់ខូចអត់ធ្វើទេ ។

វិសាល ៖ ពេលគេយកអ៊ំទៅម្តាយអីអត់មានឃាត់អីបានទេអ៊ំណែ?

អ៊ូច ៖ ឃាត់អត់បានទេ បើគេប្រមូលផ្តុំទូទៅហើយ ។

វិសាល ៖ ទូទៅតែម្តង អញ្ចឹងឲ្យកូនទៅៗ?

អ៊ូច ៖ ឲ្យកូនទៅ ។

វិសាល ៖ បាទ ចុះដល់ពេលបងប្អូនគេឲ្យនៅដែរអត់ ប្អូនបងអ៊ំអីណា?

អ៊ូច ៖ អត់ទេអាហ្នឹងគេប្រមូលផ្តុំនារីគេទៅនារីទៅ ។

វិសាល ៖ នារី?

អ៊ូច ៖ បាទ! ក៏ប៉ុននៅក្នុងកុមារទេណា ។

វិសាល ៖ បាទ ទៅធ្វើការហ្នុងនៅចាំបានទេថា ធ្វើអីខ្លះនៅកន្លែងហ្នឹង?

អ៊ូច ៖ ធ្វើស្រែចំការដូចគ្នា ។

វិសាល ៖ ធ្វើស្រែចំការដូចគ្នា លក្ខខ័ណការងារហ្នឹងយ៉ាងម៉េចដែរ អ៊ំធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

អ៊ូច ៖ ពេលពីម៉ោងប្រាំមួយហ្នឹងដល់ម៉ោងដប់ដប់មួយបានមកកន្លែងស្នាក់នៅវិញ ។

វិសាល ៖ ចេញទៅម៉ោងប្រាំមួយមានបានហូបអីពេលព្រឹកទេ?

អ៊ូច ៖ អត់មានទេ ។

វិសាល ៖ អត់ទេ?

អ៊ូច ៖ បាទ ទាល់តែម៉ោងដប់មួយបានៗហូប ។

វិសាល ៖ ម៉ោងដប់មួយបានហូបហ្នឹងហូបបាយ ឬក៏បបរដែរ?

អ៊ូច ៖ អ៊ឺ កាលជំនាន់ហ្នឹងអត់ទាន់មានបបរទេបាយ ។

វិសាល ៖ កាលគេឲ្យហូបមួយវែ្ធត ឬក៏យ៉ាងម៉េច?

អ៊ូច ៖ ម៉ាវែ្ធត ។

វិសាល ៖ ម៉ាវែ្ធត ហើយម្ហូបវិញបានអីខ្លះ?

អ៊ូច ៖ ម្ហូបអត់ទៀងជួនកាលមានត្រីជួនកាលមានសាច់អញ្ចឹងទៅ ។

វិសាល ៖ អូ!

អ៊ូច ៖ មានបន្លែមានផ្លាស់ប្ដូរគ្នាអញ្ចឹងទៅ ។

វិសាល ៖ បាទ!

អ៊ូច ៖ ជួនកាលគ្រប់ជួនកាលត្រកួនព្រលិត ។

វិសាល ៖ ដល់ពេលហូបហើយទៅធ្វើការវិញម៉ោងប៉ុន្មាន?

អ៊ូច ៖ ហើយម៉ោងពីរចាប់ធ្វើការ ។

វិសាល ៖ ម៉ោងពីរ?

អ៊ូច ៖ ដល់ម៉ោងប្រាំ ។

វិសាល ៖ ហើយបានមកបានបាយហូបទៀតទៅ?

អ៊ូច ៖ មកវិញបានបាយហូប ។

វិសាល ៖ អញ្ចឹងអត់តែអាហារពេលព្រឹកទេ?

អ៊ូច ៖ អត់មាន ។

វិសាល ៖ តែបើថ្ងៃហើយល្ងាចគឺម៉ាវែ្ធតៗ ចុះយប់ត្រូវធ្វើការទៀតទេ??

អ៊ូច ៖ កាលហ្នឹងអត់ទាន់មានធ្វើការយប់ទេ យប់សម្រាក ។

វិសាល ៖ យប់សម្រាក?

អ៊ូច ៖ បាទ!

វិសាល ៖ ការងារហ្នឹងហត់នឿយទេ ឬមួយក៏ច្រើនទេ?

អ៊ូច ៖ ការងារអស់នេះរបបវាធ្វើរាល់ថ្ងៃទៅមធ្យម ។

វិសាល ៖ បាទៗ គេអត់មានកំនត់ថាមួយថ្ងៃម្នាក់ត្រូវធ្វើហើយប៉ុន្មានៗអត់ទេ?

អ៊ូច ៖ អត់ទេ ធ្វើរួមទាំងអស់គ្នា ។

វិសាល ៖ ធ្វើរួមទាំងអស់គ្នា?

អ៊ូច ៖ បាទ!

វិសាល ៖ ហើយសុទ្ធតែក្មេងៗដូចអ៊ំអញ្ចឹងទៅ?

អ៊ូច ៖ បាទ សុទ្ធតែក្មេងៗ ។

វិសាល ៖ បាទ នៅហ្នឹងរហូតដល់ឆ្នាំណាដែរ?

អ៊ូច ៖ ឆ្នាំ៧៧ចុង៧៧ហ្នឹង ។

វិសាល ៖ ចុង៧៧?

អ៊ូច ៖ បាទ ខ្ញុំចេញទៅធ្វើទ័ព ។

វិសាល ៖ ចុង៧៧អញ្ចឹងសុំសួរអ៊ំចំនុចហ្នឹងដែរអ៊ំណា ចុង៧៧ហ្នឹងកាលណា កាលហ្នុងអ្នកណាគេអំពាវនាវឲ្យចូលធ្វើទ័ព ឬក៏គេចុចឈ្មោះឲ្យធ្វើទ័ព ឬក៏យ៉ាងម៉េចដែរ?

អ៊ូច ៖ មេកងចុចមក ។

វិសាល ៖ មេកងចុច អញ្ចឹងតាសងអ្នកចុចឈ្មោះ?

អ៊ូច ៖ បាទ ចុចយកឲ្យទៅហ្នុង ។

វិសាល ៖ ឲ្យទៅតែម្តង?

អ៊ូច ៖ ទៅខ្លះនៅខ្លះ ។

វិសាល ៖ ទៅខ្លះនៅខ្លះ ហើយអ៊ំកាលហ្នឹងគេ?

អ៊ូច ៖ គេចុចទៅ ។

វិសាល ៖ ចុចទៅ អញ្ចឹងអ៊ំនៅហ្នុងប្រហែលយូដែរអ៊ំណែនៅក្នុងកងចល័ត?

អ៊ូច ៖ នៅជាងមួយឆ្នាំ ។

វិសាល ៖ ជាងមួយឆ្នាំ កាលនៅ៧៦ដល់ចុង៧៧គេឲ្យទៅ?

អ៊ូច ៖ បាទ!

វិសាល ៖ ថាជាងមួយឆ្នាំចុះណែអ៊ំណែ ដែលបានទៅលេងផ្ទះទេ?

អ៊ូច ៖ អត់ ។

វិសាល ៖ មានបានសុំគេមកលេងទេ?

អ៊ូច ៖ មិនសុំព្រោះគេមិនឲ្យមក ។

វិសាល ៖ តែអ៊ំអត់មានសុំទេ?

អ៊ួច ៖ អត់សុំ ប៉ុនតែឃើញគេសុំអត់ឲ្យមកព្រោះម្ដាយជួនកាលគាត់អត់នៅផ្ទះដែរ គាត់ទៅរៀបចំ មើលដាំបន្លែដាំអីធ្វើការមុខជំនាញគាត់ទៅណា ។

វិសាល ៖ បាទ!

អ៊ួច ៖ បាទ សុំគេមិនឲ្យមកទេ ។

វិសាល ៖ តែពីកន្លែងនោះមកហ្នឹងប្រហែលប៉ុន្មានគីឡូដែរ?

អ៊ួច ៖ ឆ្ងាយដែរភូមិអន្លង់ប្រាសាទមកយើងនេះឆ្ងាយដែរ ។

វិសាល ៖ បើដើរប្រហែលប៉ុន្មានថ្ងៃដែរ?

អ៊ួច ៖ ដើរមួយព្រឹកថ្ងៃត្រង់ដល់ ។

វិសាល ៖ តាំងពីព្រឹកដល់ថ្ងៃត្រង់?

អ៊ួច ៖ បាទ!

វិសាល ៖ ប៉ុន្តែអត់ដែលបានមករៀនសោះ?

អ៊ួច ៖ អត់ដែលមកទេ ។

វិសាល ៖ ចុះបើមានរឿងអីកើតឡើងចំពោះបងប្អូន?

អ៊ួច ៖ បើបងប្អូនឈឺអត់ដឹងទេ ។

វិសាល ៖ បាទ!

អ៊ួច ៖ ទោះបីជាបងប្អូនឈឺជាក៏អត់ដឹង ។

វិសាល ៖ តែអ៊ំធ្វើការហ្នឹងដែលឈឺទេ?

អ៊ួច ៖ ដែលដែរ ។

វិសាល ៖ ឈឺអីគេដែរកាលហ្នឹង?

អ៊ួច ៖ គ្រុន ។

វិសាល ៖ គ្រុន?

អ៊ួច ៖ គ្រុនចាញ់ ។

វិសាល ៖ គ្រុនចាញ់ដែរ?

អ៊ួច ៖ អ៊ឺ!

វិសាល ៖ តែមានថ្នាំព្យាបាលអីទេ?

អ៊ួច ៖ មានពេទ្យព្យាបាលតាមកងអីហ្នឹង

វិសាល ៖ កាលហ្នឹងមានចាំទេពេទ្យ?

អ៊ួច ៖ ថ្នាំ ពេទ្យអត់ស្គាល់មិនដឹងមកពីណាមក ។

វិសាល ៖ អូ តែជាដែរ?

អ៊ួច ៖ ជា ។

វិសាល ៖ បាទ! មានអ្នកគ្រុនចាញ់ច្រើនទេអ៊ំនៅហ្នឹង?

អ៊ួច ៖ ច្រើនដែរហ្នឹងវាឈឺមិនឈឺតែម្នាក់ទេវាឈឺច្រើនដែរហ្នឹង ខ្លះមានគ្រុនចាញ់ខ្លះណាចុកពោះចុកអីទៅ ។

វិសាល ៖ តែភាគច្រើនពេទ្យជួយសង្គ្រោះបាន ឬក៏មានអ្នកស្លាប់ដែរអ៊ំ?

អ៊ួច ៖ មានស្លាប់តែគ្នាវាមិនអត់អីទេ បាទស្លាប់ដូចគ្នា ។

វិសាល ៖ មានអ្នកស្លាប់នៅពេទ្យច្រើនដែរ?

អ៊ួច ៖ បាទ!

វិសាល ៖ អ៊ំឃើញផ្ទាល់ភ្នែកតែម្តង?

អ៊ួច ៖ អ៊ឺ!

វិសាល ៖ ពេទ្យហ្នឹង កាលហ្នឹងពេទ្យឈ្មោះអីដែរអ៊ំពេទ្យ?

អ៊ួច ៖ អត់ស្គាល់យើងអត់ដែលស្គាល់គេផង ។

វិសាល ៖ តែពេទ្យគេហៅពេទ្យមូលដ្ឋាន ពេទ្យទាហាន ឬក៏ពេទ្យអីដែរអាចចាំទេ?

អ៊ួច ៖ ពេទ្យមូលដ្ឋានពេទ្យរដ្ឋ ពេទ្យមូលដ្ឋានហ្នឹង ។

វិសាល ៖ ពេទ្យមូលដ្ឋាន កាលហ្នឹងគេមានដូចជាមន្ទីរពេទ្យអីត្រឹមត្រូវ ឬក៏?

អ៊ួច ៖ បាទ មន្ទីរពេទ្យ ។

វិសាល ៖ អូ! ដែលៗចូលទៅក្នុងទេ?

អ៊ួច ៖ យកមកដេកនៅក្បាលដីហ្នឹង កន្លែងមន្ទីរពេទ្យគេមាននៅហ្នឹងមួយដែរ ។

វិសាល ៖ ក្បាលដី?

អ៊ួច ៖ អ៊ឺ!

វិសាល ៖ អាពេលគ្រុនចាញ់ហ្នឹងអ៊ំណែ?

អ៊ួច ៖ គ្រុនចាញ់ ។

វិសាល ៖ ពេទ្យគេហ្នឹងយាងម៉េចដែរអ៊ំ?

អ៊ូច ៖ ពេលចាក់ថ្នាំអាថ្នាំដាក់ក្នុងដបទឹកក្រូចយើងពីដើមហ្នឹង អាដបទឹកនេះយើងហ្នឹងថ្នាំសឹងមួយរយគុណនោះ អាឈើស្អីក៏ចាក់អាហ្នឹងដែរ ។

អ៊ុំស្រី ៖ ដបធំគេចេះតែបូមចាក់គ្រប់មនុស្សអញ្ចឹងទៅឲ្យតែឈឺ ។

វិសាល ៖ បាទ!

អ៊ូច ៖ បូមចាក់អញ្ចឹងទៅ ហើយបើថាដូនកាលថ្នាំហ្នឹងជាតិថ្លៃដូនយើងវាបេះមកទាំងធ្លាយអញ្ចឹងហើយ កាប់ហើយបូមដាក់ក្នុងសារ៉ាំងហើយយកមកចាក់ឲ្យយើងអញ្ចឹងមក ។

វិសាល ៖ គេចាក់អ៊ំអញ្ចឹងដែរ?

អ៊ូច ៖ ខ្ញុំឃើញគេចាក់អញ្ចឹងដែរដូចគ្រុនចាញ់អីតែខ្ញុំអត់បានចាក់ទេ ខ្ញុំចាក់អាថ្នាំដប ។

វិសាល ៖ បាទៗ! នៅហ្នុងយូទេ?

អ៊ូច ៖ នៅដេកប្រហែលកន្លះខែជាង ។

វិសាល ៖ អូ! កន្លះខែជាង បាទ ហើយទៅបានមកវិញ?

អ៊ូច ៖ មកវិញមកកងវិញ ។

វិសាល ៖ បាទៗ ត្រលប់ទៅសុំសួរអំរឿងអាពេលអ៊ី ពេលចុះឈ្មោះអ៊ំឲ្យទៅកាលហ្នឹងអ៊ី មេកងឈ្មោះ សង តែឥលូវហ្នឹងអ៊ំគិតថាគាត់ប្រហែលជានៅផ្សារទម្លាប់ ឃុំជាប់ជុំ ជាន់ជុំ?

អ៊ូច ៖ ជាន់ជុំ ។

វិសាល ៖ ឃុំជាន់ជុំ ស្រុកគីរីវង្ស?

អ៊ូច ៖ ប៉ុនខ្ញុំមិនដែលឃើញទេតែបងមួយនោះ ខ្ញុំមិនដែលឃើញទេមិនដែលជួបទេខ្ញុំ ។

វិសាល ៖ បាទៗ មិនដែលជួបទេ តែបើពេលជួបអាចចំណាំមុខគាត់ទេ?

អ៊ូច ៖ ទេមិនដឹងម៉េចទេព្រោះវាចាស់ដែរហើយ ។

វិសាល ៖ បាទ! ពេលគេចុចឈ្មោះហ្នឹង ចុចទៅគេមាននិយាយថាអីទេ ឬក៏អីដែរអ៊ំ?

អ៊ូច ៖ ពេលគេចុចគេមាននិយាយអីគេថាទៅទ័ពអញ្ចឹងហ្នង ។

វិសាល ៖ ទៅទ័ព?

អ៊ូច ៖ អ៊ឺ!

វិសាល ៖ ហើយអ៊ំមានប្រកែកមានអីទេ?

អ៊ូច ៖ ប្រកែកក៏ប្រកែកមិនកើតដែរគេចុចហើយ ។

វិសាល ៖ បាទ! កាលហ្នឹងពីក្នុងកងអ៊ំក្នុងចំណោមមួយរយនាក់ហ្នឹងគេរើសប៉ុន្មានដែរទៅអ៊ំ?

អ៊ូច ៖ ដប់ប្រាំនាក់ម្ភៃនាក់អី ។

វិសាល ៖ ម្ភៃនាក់?

អ៊ូច ៖ ទៅមួយវគ្គៗអញ្ចឹងទៅ ។

វិសាល ៖ ទៅមួយវគ្គៗ?

អ៊ូច ៖ បាទ!

វិសាល ៖ រើសមួយវគ្គៗអញ្ចឹងមួយវគ្គហ្នឹងប្រហែលប៉ុន្មានខែទៅអ៊ំបានគេរើសម្តង ឬក៏អាចចាំទេ?

អ៊ូច ៖ មិនទៀងៗ ។

វិសាល ៖ មិនទៀង អញ្ចឹងឈ្មោះ សង ហ្នឹងរើសទៅអ៊ំក៏ទៅៗ?

អ៊ូច ៖ ទៅ ។

វិសាល ៖ ហើយមានស្គាល់អ្នកក្នុងភូមិហ្នឹងដែលទៅធ្វើទាហានទេ?

អ៊ូច ៖ ភូមិយើងទៅស្លាប់អស់ហើយតាមហ្នឹងអីទៅស្លាប់អស់ហើយ ។

វិសាល ៖ អ៊ំ ខន អីនេះនៅ?

អ៊ូច ៖ នៅ ។

វិសាល ៖ អូ បាទ ស្លាប់អស់ហើយពេលគេរើសអ៊ំដូចថាគេបញ្ជូនអ៊ំទៅ មានទៅហាត់ហ៊ឹកហ៊ឺនអីនៅណាសិនទេ ឬក៏ទៅបាញ់យកតែម្តង?

អ៊ូច ៖ ទៅនៅវត្តតាអូរទៅដល់ឲ្យកាន់កាំភ្លើងយកហ្មង ។

វិសាល ៖ ទៅវត្តអូរ?

អ៊ូច ៖ វត្តតាអូរ ។

វិសាល ៖ វត្តតាអូរ?

អ៊ូច ៖ បាទ ទៅនៅហ្នុង ។

វិសាល ៖ ទៅនៅហ្នុង វត្តតាអូរហ្នឹងនៅក្នុងភូមិឃុំអីដែរទៅអ៊ំ?

អ៊ូច ៖ ឃុំតាអូរ ។

វិសាល ៖ ឃុំតាអូរ

អ៊ូច ៖ ភូមិតាអូរហ្មង ។

វិសាល ៖ ភូមិតាអូរស្រុកគិរីវង្សដែរ?

អ៊ូច ៖ ស្រុកគិរីវង្សដែរ ។

វិសាល ៖ ពេលចេញទៅហ្នឹងគេមកដឹកឡានទៅ ឬក៏គេឲ្យដើរទៅ?

អ៊ូច ៖ អ៊ឺ ទេះសេះ ។

វិសាល ៖ រទេះសេះ?

អ៊ូច ៖ បាទ!

វិសាល ៖ ចេញទៅប៉ុន្មានរទេះសេះដែរចាំទេអ៊ំ?

អ៊ូច ៖ អូ ភ្លេចអស់ហើយដឹងប៉ុន្មាន រទេះសេះហ្នឹងទៅម្តងរទេះសេះពីរអីហ្នឹង ។

វិសាល ៖ ពីរអាចថា?

អ៊ូច ៖ ប្អូនដប់នាក់ម្ភៃនាក់ដីហ្នឹង ។

វិសាល ៖ អញ្ចឹងប្រហែលជាម្ភៃនាក់ចេញទៅ?

អ៊ូច ៖ បាទ!

វិសាល ៖ ក្មេងៗដូចអ៊ំអញ្ចឹង?

អ៊ូច ៖ ហ្នឹងហើយក្មេងៗដូចគ្នា ។

វិសាល ៖ ប្រុសៗ?

អ៊ូច ៖ ប្រុសៗដូចគ្នា ។

វិសាល ៖ បាទ ពេលចេញទៅហ្នឹងគឺរទេះសេះអត់មានថាទាហានអីទៅតាមជាមួយអីក៏អត់ទេអ៊ំ?

អ៊ូច ៖ អត់ទេតែឲ្យទៅៗធម្មតាហ្នុង ។

វិសាល ៖ បាទៗ ហើយទៅដល់វត្តនោះឲ្យកាំភ្លើងហ្នុង?

អ៊ូច ៖ ទៅដល់ឲ្យកាំភ្លើង ។

វិសាល ៖ កាំភ្លើង កាំភ្លើងអីទៅអ៊ំ?

អ៊ូច ៖ កាំភ្លើងមានអិមស៊ីក៏មាន អាកាក៏មាន ។

វិសាល ៖ ហើយអ៊ំបានកាំភ្លើងអីដែរ?

អ៊ូច ៖ អាកា ។

វិសាល ៖ អ៊ំបានអាកា គេឲ្យអញ្ចឹងមានដឹងរបៀបប្រើទេ ឬក៏អត់ទេ?

អ៊ូច ៖ គេណែនាំ ។

វិសាល ៖ គេណែនាំ?

អ៊ូច ៖ គេណែនាំលើកហេតុផល ។

វិសាល ៖ មានចាំទេគេមានហេតុផលអីខ្លះ?

អ៊ូច ៖ ហេតុផលរឿងគោលការបាញ់អីផ្លូវជិតផ្លូវឆ្ងាយ បច្ចេកទេស ។

វិសាល ៈ បាទ!

អ៊ូច ៈ ដល់ពីហ្នឹងមកឲ្យហ្នឹកហ្នឹនដែររៀនបាញ់ស៊ីប ។

វិសាល ៈ បាញ់ស៊ីប?

អ៊ូច ៈ បាទ!

វិសាល ៈ នៅណាទៅនៅវត្តហ្នឹងដែរ?

អ៊ូច ៈ មកបាញ់ស៊ីបនៅត្រពាំងញិញ ។

វិសាល ៈ ត្រពាំងញិញវិញ?

អ៊ូច ៈ បាទ!

វិសាល ៈ នៅវត្តត្រពាំងអីអូរនោះប្រហែលប៉ុន្មានថ្ងៃដែរទៅ?

អ៊ូច ៈ អូ ដីប្រហែលបួនគីឡូទៅដល់ត្រពាំងញិញ ។

វិសាល ៈ តែនៅវត្តហ្នឹងប្រហែលប៉ុន្មានថ្ងៃបានគេបញ្ជូនមកបាញ់ស៊ីប?

អ៊ូច ៈ មកប្រហែលកន្លះខែ ។

វិសាល ៈ កន្លះខែ អញ្ចឹងកន្លះខែនៅហ្នឹងមានស្គាល់គេទេអ្នកបង្វឹកអី?

អ៊ូច ៈ ស្គាល់ដែរប៉ុន្តែស្គាល់នៅឆ្ងាយដូចថាស្រុកនេះមួយស្រុកនោះមួយ ជួបគ្នាអញ្ចឹងទៅអញ្ចឹង ។

វិសាល ៈ គ្រូដេលបង្រៀនអីណាគាត់បង្ហាញឲ្យបាញ់ជិតបាញ់ឆ្ងាយយ៉ាងម៉េចហ្នឹងស្គាល់គេទេ?

អ៊ូច ៈ អត់ ។

វិសាល ៈ អត់ស្គាល់ទេ?

អ៊ូច ៈ គ្រូថ្មីកាលពីដើមអត់រៀនហ្នឹងផង ។

វិសាល ៈ អូ តែពួកគាត់ហ្នឹងសុទ្ធតែទាហានហើយ?

អ៊ូច ៈ ទាហានទូទៅទាំងអស់ ។

វិសាល ៈ អូ នៅក្នុងវត្តហ្នឹងមានទាហានខ្មែរក្រហមប៉ុន្មាននាក់ទៅអី?

អ៊ូច ៈ មិនដឹង បើកន្លែងខ្ញុំនៅប្រហែលជាហាសិបនាក់ហើយដឹង វាដាក់កន្លែងឲ្យនៅមួយក្រុមៗ អញ្ចឹងទៅ ។

វិសាល ៈ មួយក្រុមៗ?

អ៊ូច ៈ អ៊ឺ!

វិសាល ៈ ហាសិបនាក់ហ្នឹងតែក្មេងៗគ្នាអីទេ ឬក៏ហាសិបនាក់ទាំងទាហានគេដែរ?

អ៊ូច ៈ សរុបៗគ្នាទាំងអស់ ។

វិសាល ៖ សរុបគ្នាទាំងអស់?

អ៊ូច ៖ យើងទៅសារីក្រោយអ្នកមុនអ្នកដឹកនាំ ។

វិសាល ៖ បាទ!

អ៊ូច ៖ គេអ្នកជំនាន់ចាស់អ្នកដឹកនាំ ។

វិសាល ៖ នៅក្នុងសុទ្ធតែប្រុសៗទាំងអស់?

អ៊ូច ៖ សុទ្ធតែប្រុសៗទាំងអស់ ។

វិសាល ៖ បាទៗ នៅបានកន្លះខែក្រោយពីគេណែនាំឲ្យបាញ់ជិតបាញ់ឆ្ងាយ គេមានណែនាំឲ្យអីទៀតទេ?

អ៊ូច ៖ ណែនាំលើកហេតុផលឲ្យ ។

វិសាល ៖ ហេតុផលម៉េចទៅអ៊ំ?

អ៊ូច ៖ ហេតុផលថាយើងបាញ់ជិតគិតតាមជិតបើឆ្ងាយលើកតាមឆ្ងាយ ហេតុផលរឿងក្រលាអូសក្រលាអីហ្នឹងផ្លូវជិតផ្លូវឆ្ងាយ ។

វិសាល ៖ អូ!

អ៊ូច ៖ ហ្នឹងគោលដៅគេប្រគល់ឲ្យអញ្ចឹងតែមិនទាន់ចេញទៅវៃទេ ។

វិសាល ៖ មិនទាន់ចេញទៅវៃទេ ដោះកាំភ្លើងដោះអី?

អ៊ូច ៖ ដោះកាំភ្លើងដោះអីលាងសព្វគ្រប់ ។

វិសាល ៖ ចេះ?

អ៊ូច ៖ រៀនដោះកាំភ្លើងដោះអី ។

វិសាល ៖ ហើយអ៊ំចេះដែរ?

អ៊ូច ៖ ចេះ ។

វិសាល ៖ ហើយផ្នកក្មេងៗជិតអ៊ំហ្នឹងក៏ចេះ?

អ៊ូច ៖ ចេះដូចគ្នាអញ្ចឹង ។

វិសាល ៖ ចេះដូចគ្នា?

អ៊ូច ៖ ប៉ុនអ្នកណាអ្នកហ្នឹងកាន់ ។

វិសាល ៖ បាទៗ ក្រៅពីកាំភ្លើងគេមានបង្រៀនឲ្យផ្សេងអីទៀតទេពេលហ្នុង?

អ៊ូច ៖ អត់មានអីទេ ។

វិសាល ៖ ដូចគ្រាប់បែកគ្រាប់អីមានទេ?

អ៊ួច ៖ អត់ទាន់មានទេ ។

វិសាល ៖ អត់ទាន់មានទេ?

អ៊ួច ៖ គេអត់ទាន់ឲ្យប្រើប្រាស់ព្រោះយើងអត់មានកម្លាំងដៃបោក ។

វិសាល ៖ បាទ អញ្ចឹងគឺនៅកន្ទះខែហ្នឹងតែបាញ់កាំភ្លើងជិតឆ្ងាយ ហើយនឹងដោះកាំភ្លើងទេ?

អ៊ួច ៖ បាទគ្រាន់តែរៀនដោះកាំភ្លើង ។

វិសាល ៖ បាទ ហើយបន្ទាប់មកទៀតបានបញ្ជូនទៅណា?

អ៊ួច ៖ មកបាញ់ស៊ីបនៅឯត្រពាំងញ៉ិញ ។

វិសាល ៖ ត្រពាំងញ៉ិញ អ្នកបញ្ជូនអ៊ំមកវិញហ្នឹងស្គាល់គេទេ?

អ៊ួច ៖ ស្គាល់ៗ ។

វិសាល ៖ គាត់ឈ្មោះអីទៅ?

អ៊ួច ៖ ឈ្មោះរឹម ។

វិសាល ៖ គាត់នៅរស់ទេអ៊ំ?

អ៊ួច ៖ អត់ដឹងស្រុកគេនៅអន្លុងវែងដែលស្គាល់ផង ។

វិសាល ៖ អូ!

អ៊ួច ៖ កាលហ្នឹងគេធ្វើប្រធាន ។

វិសាល ៖ គេជាប្រធានឈ្មោះ រឹម ជាប្រធាន?

អ៊ួច ៖ បាទ!

វិសាល ៖ នៅវត្ត?

អ៊ួច ៖ នៅអន្លុងវែងនោះប៉ុន្តែមិនដែលជួបគ្នាទេ ។

វិសាល ៖ អត់ដែលជួបទេ?

អ៊ួច ៖ តាំងពីចុះមកពី៧៩មកអត់ដែលជួបទេ ។

វិសាល ៖ បាទៗ បញ្ជូនមកវិញបញ្ជូនអ្នកពីររទេះសេះដដែលហ្នឹងមិនមែនអ៊ំ?

អ៊ួច ៖ អត់ទេគ្នាច្រើនដាក់ឡាន ។

វិសាល ៖ អូ មកវិញឡានហ្នឹង?

អ៊ួច ៖ ឡាន ។

វិសាល ៖ ប៉ុន្មានឡានទៅអាចចាំទេ?

អ៊ួច ៖ បីបួនប្រាំឡានទៅ ។

វិសាល ៖ អញ្ចឹងអាចថាច្រើនណែអឹណែ?

អ៊ូច ៖ ច្រើន ឡានទៅមួយក្រុមៈអញ្ចឹងទៅ ។

វិសាល ៖ អូ អញ្ចឹងដឹនាន់អ៊ីបញ្ជូនចេញពីវត្តនោះវិញអាចហាហុកសិបនាក់ទេអ៊ី?

អ៊ូច ៖ បាទ ប្រហែលហាហុកសិបនាក់ហ្នឹងហើយ ។

វិសាល ៖ ហើយទៅបាញ់ស៊ីបនៅណាវិញទៅអ៊ី?

អ៊ូច ៖ បាញ់នៅក្នុងភ្នំហ្នុង ។

វិសាល ៖ ភ្នំ?

អ៊ូច ៖ កណ្តាលភ្នំហ្នុង ។

វិសាល ៖ បាទ!

អ៊ូច ៖ កណ្តាលភ្នំវាមានជ្រោះមានអូរអីហើយមានកាប់ចម្ការដាំពោតដាំឥឡឹកអី ដឹឡូងអីអញ្ចឹងទៅ ហើយទៅបាញ់កន្លែងហ្នឹង ។

វិសាល ៖ ហ៊ឹកហ៊ឹន មានស្គាល់មេគ្រប់គ្រងនៅហ្នុងទេ?

អ៊ូច ៖ មេអត់ ។

វិសាល ៖ អត់ស្គាល់ទេ?

អ៊ូច ៖ បាទ ។

វិសាល ៖ តែពួកហ្នឹងនៅហ្នុងសុទ្ធតែទាហានហើយ?

អ៊ូច ៖ សុទ្ធតែទាហានខោអាវស្លៀកសុទ្ធតែទាហានអញ្ចឹងហ្នុង ។

វិសាល ៖ អូ បាទៗ ទៅហ្នុងក្រៅពីបាញ់ស៊ីបគេបង្រៀនឲ្យបាញ់ស៊ីបមានធ្វើអីទៀតទេអ៊ី?

អ៊ូច ៖ អត់ទេគ្រាន់តែការបែកខទេសរឿងវៃតិចតួចហ្នឹងប្រាប់ដំណើរ រឿងការលូនចូលទៅវៃយ៉ាងម៉េចដកចេញវៃយ៉ាងម៉េចប៉ុនហ្នឹង ។

វិសាល ៖ គេមានសរសេរលើក្តាខៀនពន្យល់អីទេ ឬក៏មានចែកជាសៀវភៅអីទេគេឲ្យទេអ៊ី?

អ៊ូច ៖ អត់ៗ ។

វិសាល ៖ អត់មានទេ?

អ៊ូច ៖ អត់ ។

វិសាល ៖ នៅហ្នឹងដូចថាទៅអញ្ចឹងគេមានថតរូបថតអីទេអ៊ី?

អ៊ូច ៖ អត់មានទេអត់ថតអត់អីទេជំនាន់ហ្នឹង ។

វិសាល ៖ អូ បាទក្រែងលោមានថតរូបថតអីអញ្ចឹង ក្រែងលោមានសល់រូបថតអីអញ្ចឹងខ្ញុំអាចសុំ?

អ៊ូច ៖ អត់ៗ ។

វិសាល ៖ អត់មានទេ?

អ៊ូច ៖ អត់ ។

វិសាល ៖ បាទៗ អ៊ំនៅហាត់ហ្នឹងក្មេងៗស្រករៗអ៊ំមានប្រហែលជាប៉ុន្មាននាក់ទៅអ៊ំ?

អ៊ូច ៖ ប្រហែលជាពីររយនាក់ ។

វិសាល ៖ ពីររយនាក់?

អ៊ូច ៖ ចុះមួយស្រុកគិរីវង្ស?

វិសាល ៖ គិរីវង្សបាទៗ គេមានបង្រៀនយោធាតិចនិចបាញ់ហើយគេមានបំពាក់បំប៉ននយោបាយអីមានទេ?

អ៊ូច ៖ បំពាក់បំប៉ន ការដើម្បីយើងរើបចេ្ចកទេសការឆ្លងកាត់ធ្វើសង្រ្គាម ។

វិសាល ៖ អាហ្នឹងទាក់ទងខាងយោធា?

អ៊ូច ៖ ខាងយោធា ។

វិសាល ៖ ចុះបើនិយាយពីនយោគោលនយោបាយរបស់គេ គេបំពាក់បំប៉នឲ្យយ៉ាងម៉េចមានទេអ៊ំ?

អ៊ូច ៖ គោលនយោបាយជំនាន់អាពតមានអី មានតែឲ្យយើងជឿជាក់លើអាពត ។

វិសាល ៖ អញ្ចឹងអាហ្នឹងមានដែរ?

អ៊ូច ៖ មាន ។

វិសាល ៖ មានប្រជុំឲ្យជឿជាក់?

អ៊ូច ៖ បាទ ឲ្យជឿជាក់លើខ្មែរយើងហ្នឹង ។

វិសាល ៖ កាលហ្នឹងគេមានបង្រៀនពីវិន័យទ័ពត្រូវស្តាប់មេស្តាប់កើយអីទេ?

អ៊ូច ៖ ស្តាប់មានការបចេ្ចកទេស ។

វិសាល ៖ តឹងតែងទេ?

អ៊ូច ៖ តឹងតែងដែរ ។

វិសាល ៖ អូ!

អ៊ូច ៖ តឹងតែងថាអ៊ីមួយការរើសង្រ្គាមមកពីមុខអញ្ចឹងទៅបើថាមេមិនដកយើងអត់ដកទេ ។

វិសាល ៖ បាទ!

អ៊ូច ៖ បើថាត្រូវរបួសត្រូវអីស្លាប់រស់ហ្នឹងគឺសែងគ្នាយកមកឲ្យបានដល់កន្លែងតាមក្រោយ ។

វិសាល ៖ បាទ គេមានអញ្ចឹង?

អ៊ូច ៖ មានអញ្ចឹងការលើកហេតុផលណែនាំ ។

វិសាល ៖ ទៅហាត់ហ្នឹងរយៈពេលប៉ុន្មានដែរទៅអ៊ីមួយចប់?

អ៊ូច ៖ មួយខែ ។

វិសាល ៖ មួយខែ?

អ៊ូច ៖ បាទ!

វិសាល ៖ តែគ្រាប់បែកនៅតែអត់បោក?

អ៊ូច ៖ អត់បោកទេបច្ចេកទេសខ្ចី ទាល់តែពួកគេចាស់ៗ ។

វិសាល ៖ ចាស់ៗ អញ្ចឹងក្រុមអីក្មេងៗកាន់តែកាំភ្លើង?

អ៊ូច ៖ កាន់តែកាំភ្លើងហើយនឹងគ្រាប់ ។

វិសាល ៖ គ្រាប់ ហាត់ហើយមួយខែហ្នឹអី?

អ៊ូច ៖ បាទ!

វិសាល ៖ មួយខែគិតថាប្រហែលជាស្គាល់គេច្រើនហើយ?

អ៊ូច ៖ ស្គាល់ច្រើនដែរ ។

វិសាល ៖ បាទៗ មានៗស្គាល់ឈ្មោះអ្នកដែលនៅរស់ក្រៅពភូមិហ្នឹងទេអី?

អ៊ូច ៖ ស្គាល់ នេះពួកនេះមួយជំនៀនេះង៉ាប់អស់ហើយ ។

វិសាល ៖ ស្លាប់អស់ច្រើនតែម្តង?

អ៊ូច ៖ ស្លាប់អស់ច្រើកាលវៃវៀតណាមកាល៧៨-៧៩ហ្នឹង ។

វិសាល ៖ បាទ អញ្ចឹងបន្ទាប់ពីហាត់មួយខេហើយគេបញ្ជូនទៅណាទៀតទៅ?

អ៊ូច ៖ ទៅព្រំដែន ។

វិសាល ៖ ព្រំដែនវៀតណាម?

អ៊ូច ៖ ព្រំដែនវៀតណាម ។

វិសាល ៖ បញ្ជូនទៅវៃហ្នុង ឬក៏បញ្ជូនទៅឈដើងទេ?

អ៊ូច ៖ បញ្ជូនទៅឈដើង ។

វិសាល ៖ ឈដើង?

អ៊ូច ៖ ឈដើងក្បែមាត់ព្រែក ។

វិសាល ៖ ក្បែមាត់ព្រែក?

អ៊ូច ៖ បាទ វានៅព្រែកម្ខាងយើងនៅព្រែកម្ខាង ។

វិសាល ៖ អូ កាលនៅធ្វើជាទាហានហ្នឹងគឺហូបចុកអីគឺបរិបូរគ្រប់គ្រាន់ទេអ៊ំណែ?

អ៊ូច ៖ ធម្មតា ។

វិសាល ៖ មានអាហារពេលព្រឹកទេ?

អ៊ូច ៖ អ៊ឺ អត់ទេ ។

វិសាល ៖ អាហារពេលព្រឹកអត់ដែរ?

អ៊ូច ៖ បាទ ព្រោះសេដ្ឋកិចគេនៅក្រោយដល់ពេលកងកុមារហ្នឹងគេថា ឥលូវគេថាឡើងដាំបាយ អញ្ចឹងដាំបាយដាក់ហូបនឹងស្ពុក អត់មានឆ្នាំងមានយកទៅឲ្យទេគឺដាក់ស្ពុក ។

វិសាល ៖ បាទ នៅឈរជើងដំបូងនៅឈរជើងព្រំដែនជាមួយវៀតណាម?

អ៊ូច ៖ បាទ កាលហ្នឹងសង្គ្រាមជាមួយវៀតណាម ។

វិសាល ៖ កាលហ្នឹងមានសង្គ្រាមបាញ់គ្នាហើយ ។

អ៊ូច ៖ បាញ់គ្នា ។

វិសាល ៖ អញ្ចឹងគេឲ្យអ៊ំទៅឈរជើងពេលទៅឈរជើងហ្នឹងគឺផ្ទុះសង្គ្រាមហើយ ឬក៏នៅទេ?

អ៊ូច ៖ ផ្ទុះសង្គ្រាមបាញ់គ្នារាល់ថ្ងៃ ។

វិសាល ៖ បាញ់រាល់ថ្ងៃ?

អ៊ូច ៖ បាទ ។

វិសាល ៖ អញ្ចឹងអ៊ំនៅបាញ់នៅហ្នុងដែរទៅ?

អ៊ូច ៖ នៅខ្ញុំជីកត្រង់សេធម្មតាអញ្ចឹងទៅ ។

វិសាល ៖ បាទ ហើយចូលរួមបាញ់នឹងគេដែរទៅ?

អ៊ូច ៖ បាទ!

វិសាល ៖ ហើយបន្ទាប់មកមានរឿងអីកើតឡើងទៀតទេលោកអ៊ំ?

អ៊ូច ៖ មានអីដល់តែ៧៩ ៧៩វៀតណាមបុករុកចូលយើងចេះតែបាក់ទ័ពចេះតែទៅៗៗ ។

វិសាល ៖ តែមានបានវៃចូលដល់វៀតណាមអីទេ?

អ៊ូច ៖ អត់នៅត្រឹមមាត់ព្រែកហ្នឹង ។

វិសាល ៖ អត់បានចូលដល់វៀតណាមទេ?

អ៊ូច ៖ ត្រឹមនៅតែមាត់ព្រែក ។

វិសាល ៖ អូ

អ៊ូច ៖ ប៉ុនតែកម្លាំងគេទៅៗកម្លាំងគេវៃចូលៗប៉ុនយើងនៅចាំត្រង់សេអញ្ចឹង ។

វិសាល ៖ អញ្ចឹងអ៊ំៗអត់បាន កម្លាំងអ៊ំគេឲ្យនៅខាងក្រោយទេ?

អ៊ូច ៖ បាទ ក្មេងៗនៅក្រោយ ។

វិសាល ៖ មិនមែនចូលទៅវ៉ៃដល់វៀតណាមដូចអីណាអ្នកផ្សេងទេ ទៅដល់ដីវៀតណាមអីអត់ទេ?

អ៊ូច ៖ ហ្នឹងកម្លាំងគេចូលទៅៗ បើកម្លាំងយើងក្មេងៗគេអត់ឲ្យទៅនៅក្រោយ ។

វិសាល ៖ នៅក្រោយទេ?

អ៊ូច ៖ បាទ!

វិសាល ៖ បាទៗ កាលហ្នឹងមានចាំទេអ៊ំថាកម្លាំងគេបុក យើងបុកចូលទៅវៀតណាមច្រើនដែរទេ ឬក៏យ៉ាងម៉េច?

អ៊ូច ៖ ទៅតាមមុខសញ្ញាអញ្ចឹងទៅទៅច្រើនដែរប៉ុនរបួសច្រើន ស្លាប់ៗច្រើនដល់តែវៀតណាមបុកមកវិញចោលខ្មោចខ្លះទៅអារត់រួចៗអាណារត់មិរួចនៅស្លាប់ហ្នឹងចោលទៅ ។

វិសាល ៖ បាទ ប៉ុន្តែខាងយើងបានវ៉ៃចូលទឹកដីវៀតណាមមែន?

អ៊ូច ៖ ចូលដល់មែន ។

វិសាល ៖ អូ កាលហ្នឹងទ័ពទៅច្រើនទេអ៊ំ?

អ៊ូច ៖ ទៅច្រើនទៅគ្រប់កងទាំងអស់ ប៉ុនតែកម្លាំក្មេងៗទប់កម្លាំងចាស់ៗបុកចូល ។

វិសាល ៖ អូ នៅខាងក្រោយ ហើយបន្ទាប់ពីគេបុកចូលបន្ទាប់ពីទ័ពចាស់ៗបុកចូលហ្នឹងយូរទេបានទ្បាច់មកវិញណាអ៊ំ ឬក៏យ៉ាងម៉េចដែរ?

អ៊ូច ៖ បីបួនថ្ងៃវៀតណាមបុកចូលមកវិញ ។

វិសាល ៖ ហើយរត់មកវិញមក?

អ៊ូច ៖ រត់មកវិញចេះតែមកៗ ។

វិសាល ៖ កាលហ្នឹងឆ្នាំណាដែរអ៊ំ?

អ៊ូច ៖ ៧៨-៧៩ ។

វិសាល ៖ អាជិតពេលដាច់ហ្នឹង?

អ៊ូច ៖ បាទជិតពេលដាច់ហ្នឹង ។

វិសាល ៖ ចុះអាសង្គ្រាមរវាងខ្មែរក្រហមនិងខ្មែរក្រហមមុន៧៩ហ្នឹងមានបានដឹងដែរអត់?

អ៊ូច ៖ អត់ដឹង ។

វិសាល ៖ អត់ដឹងទេ?

អ៊ូច ៖ អត់ដឹងខ្ញុំនៅកងកុមារតូចអត់ដឹង ។

វិសាល ៖ អញ្ចឹងអាពេលវៃជាមួយវៀតណាមគឺអាពេលជិតដាច់ហ្នឹង?

អ៊ួច ៖ បាទ

វិសាល ៖ ចូក៧/៨ហើយហ្នឹងអ៊ំ?

អ៊ួច ៖ ហ្នឹងហើយ ។

វិសាល ៖ អូ!

អ៊ួច ៖ ចូល៧/៨ចូល៧/៩ហ្នឹង ។

វិសាល ៖ បាទ ចូលបានបីថ្ងៃគេវៃវិញដាច់?

អ៊ួច ៖ វៃមកវិញដាច់បាក់ទ័ពវ៉ាវចេះតែទៅៗអញ្ចឹងទៅ វៀតគតណាមចូលពេញប្រទេសយើង អញ្ចឹងទៅវៀតណាមចូលរំដោះបានប្រទេសយើងអញ្ចឹងទៅ ។

វិសាល ៖ អ៊ំអាចចាំបានទេអ៊ំអាថ្ងៃដែល ពេលវៀតណាមបុកមកវិញមានហេតុការណ៍អីខ្លះកើតឡើងទៅអ៊ំ អ៊ំបានឃើញអីខ្លះទៅ?

អ៊ួច ៖ កើតឡើងប្រជាជនចេះតែគេចទៅយើងចេះតែរត់អញ្ចឹងដែរទៅ វាប៉ាតណាប៉ាតណីចេះតែរត់ទាំងអស់គ្នាទៅ ប្រជាជនហើយនឹងទ័ពអីចេះតែទៅ វៀតណាមចេះតែបុកចូលមានតាំងពីរថក្រោះមានអីបុក ហើយទប់វាមួយកន្លែងៗទប់មិនឈ្នះចេះតែបាក់ចេះតែទៅអញ្ចឹងទៅទៀតទៅ ។

វិសាល ៖ អញ្ចឹងមុនដំបូងឡើងអ៊ំឃើញទ័ពយើងរត់មកវិញ?

អ៊ួច ៖ បាទ

វិសាល ៖ កាលហ្នឹងពេលព្រឹកពេលយប់ ឬក៏ពេលល្ងាចដែរ?

អ៊ួច ៖ ពេលថ្ងៃបុកថ្ងៃហ្នុង ។

វិសាល ៖ ពេលថ្ងៃ?

អ៊ួច ៖ បាទ

វិសាល ៖ គេឃើញយើងរត់មកវិញគេថាយើងបាក់ហើយ?

អ៊ួច ៖ បាក់ហើយ ។

វិសាល ៖ បាទ អញ្ចឹងក្រុមអ៊ំក៏រត់?

អ៊ួច ៖ ទៅដកដែរមក ។

វិសាល ៖ អូ

អ៊ួច ៖ ដកបណ្ដើរៗមក ។

វិសាល ៖ នៅកាន់កាំភ្លើងតើពេលរត់?

អ៊ូច ៖ កាំភ្លើងនៅកាន់ធម្មតា ។

វិសាល ៖ ហើយរត់មកវិញមក?

អ៊ូច ៖ បាទ

វិសាល ៖ កាលហ្នឹងអាយុប្រហែលដប់ប៉ុន្មានដែរអ៊ំ?

អ៊ូច ៖ អេអាយុត្រឹមដប់ឆ្នាំជាងហើយ ។

វិសាល ៖ ដប់ជាង?

អ៊ូច ៖ ដប់ប្រាំបីដប់ប្រាំបួន ។

វិសាល ៖ ដប់ប្រាំបីដប់ប្រាំបួន?

អ៊ូច ៖ បាទ

វិសាល ៖ ដប់ប្រាំបីដប់ប្រាំបួនឆ្នាំអញ្ចឹងធំដែរហើយ?

អ៊ូច ៖ ធំដែរហើយ ។

វិសាល ៖ ប៉ុន្តែគេឲ្យនៅខាងក្រោយ?

អ៊ូច ៖ នៅខាងក្រោយ ។

វិសាល ៖ អត់បានចូលដល់ទឹកដីវៀតណាមទេ?

អ៊ូច ៖ អត់ ។

វិសាល ៖ បាទៗ ចង់សួរអ៊ំនៅពេលបាក់មករត់មកកាត់ផ្លូវណាខ្លះហើយទៅដល់ណាខ្លះអ៊ំ?

អ៊ូច ៖ កាត់តាមផ្លូវទម្លាប់អញ្ចឹងមកតាមគិរីវង្ស ។

វិសាល ៖ អត់មានបានរត់មកផ្ទះយើងទេ?

អ៊ូច ៖ អត់ទៅផ្ទះទៅក៏ម៉ែះអត់នៅដែរ មកក៏មិនជួបម៉ែដែរព្រោះម៉ែគាត់ទៅដែរហើយ ។

វិសាល ៖ អូ បើអញ្ចឹងកាលហ្នឹងរត់ទ័ពបាក់ច្រើន?

អ៊ូច ៖ បាក់ច្រើន ។

វិសាល ៖ រត់ហ្នឹងគេដេញប៉ោះដេះៗមក ឬក៏អត់ទេរត់បានឆ្ងាយហើយ?

អ៊ូច ៖ អាគេទប់ៗយើងដកថយៗមក ។

វិសាល ៖ មានកម្លាំងទប់ដែរ?

អ៊ូច ៖ មានគេទប់កុំឲ្យវាមកលឿនពេក ។

វិសាល ៖ អូ

អ៊ូច ៖ ហើយអាកម្មាំងថយចេះតែថយមក ។

វិសាល ៖ អញ្ចឹងអ៊ំនៅក្នុងកម្លាំងថយ?

អ៊ូច ៖ ថយយើងក្មេងៗនៅកម្លាំងថយគេចាស់ៗទប់ ។

វិសាល ៖ អូ រត់មកវិញមក?

អ៊ូច ៖ បាទ

វិសាល ៖ ដល់ពេលរត់តាមផ្លូវរត់ដល់ណាទៅអ៊ំ?

អ៊ូច ៖ ទៅដល់ស្រុកអង្គរជយនោះ ។

វិសាល ៖ អង្គរជ័យ?

អ៊ូច ៖ បាទ ។

វិសាល ៖ អង្គរជ័យនៅខេត្តតាកែវនេះដែរ?

អ៊ូច ៖ អង្គរជ័យនៅកំពត ។

វិសាល ៖ កំពត ហើយពេលរត់តាមផ្លូវអត់មានអីហូបដែរទេអ៊ំ?

អ៊ូច ៖ អ៊ី សេដ្ឋកិចយើងដាក់អង្គរដាំបាយខ្លួនឯងទៅ អង្គរម្នាក់មួយកីៗដោះស្រាយខ្លួនឯងមក ។

វិសាល ៖ ដោះស្រាយខ្លួនឯង?

អ៊ូច ៖ បាទ

វិសាល ៖ រត់ប៉ុន្មានថ្ងៃបានមកដល់ខេត្តកំពតកន្លែងអ៊ំថា?

អ៊ូច ៖ ប្រហែលជាដប់ថ្ងៃ ។

វិសាល ៖ រត់រហូត?

អ៊ូច ៖ ដើរ ។

វិសាល ៖ ដើរ?

អ៊ូច ៖ ពួកវាចេះតែវ៉ៃយើងចេះតែរំដោះទៅ ។

វិសាល ៖ មានព្យុះស្នូរគ្រាប់អីតាមផ្លូវទេ?

អ៊ូច ៖ វាផ្លោងស្មាក់បាញ់ចេះតែបាញ់ទៅហើយយើងចេះតែផ្លោងដាក់វាវិញទៅ ។

វិសាល ៖ អូ មានកាំភ្លើងធំ?

អ៊ូច ៖ បាទ មានកាំភ្លើងធំតូចដូចគ្នា ។

វិសាល ៖ ដូចគ្នា?

អ៊ូច ៖ បាទ

វិសាល ៖ តែគ្រាន់តែគ្នាគេប្រុងឈ្នះ?

អ៊ូច ៖ បាទ ប្រុងឈ្នះកម្លាំងគេវាច្រើន ។

វិសាល ៖ បាទៗ

អ៊ូច ៖ កម្លាំងយើងតិចជង ។

វិសាល ៖ ដល់ពេលដល់កន្លែងមិញអង្គរ?

អ៊ូច ៖ អង្គរជ័យ ។

វិសាល ៖ បាទ អង្គរជ័យ ដល់អង្គរជ័យឈប់សិនបានមកវិញ ឬក៏យ៉ាងម៉េចទៀត?

អ៊ូច ៖ អ៊ឺ ចុះវៀតណាមលុកលុយចូលពេញប្រទេសហើយ ចូលដល់ទីក្រុងភ្នំពេញទាំងអស់ ។

វិសាល ៖ អូ កាលហ្នឹងវៀតណាមចូលដល់ភ្នំពេញហើយ?

អ៊ូច ៖ ចូលដល់ហើយ នៅតាមផ្លូវជាតិអីពួកវាចូលដល់ ចុះបើវាវៃគ្រប់ច្រកទាំងអស់វៀតណាម ។

វិសាល ៖ អូ ហើយដល់ពេលអ៊ំនៅអង្គរជ័យហ្នឹងយ៉ាងម៉េចដែរ?

អ៊ូច ៖ ដល់ពេលនេះយើងកម្លាំងបាក់បែកអស់ហើយ យើងដោះស្រាយតាមផ្ទាល់ខ្លួនកាំភ្លើងបោះចោលទៅ ហើយមកស្រុកវិញមកតាមស្គាល់ៗគ្នាមកៗ នៅស្រុកកំណើតវិញមក ។

វិសាល ៖ អូ អញ្ចឹងអាពេលដាច់រត់ហ្នឹងអ៊ំបែកបាក់ទ័ព?

អ៊ូច ៖ បែកបាក់គ្នាអស់ហើយហ្នឹង ។

វិសាល ៖ រត់មកវិញ?

អ៊ូច ៖ រត់មកវិញ ។

វិសាល ៖ ទម្លាក់កាំភ្លើងចោលរត់មកតាមផ្លូវវិញ?

អ៊ូច ៖ ទម្លាក់កាំភ្លើងចោលមកវិ ។

វិសាល ៖ គោលបំណងមកស្រុកវិញមិនមែន?

អ៊ូច ៖ មកស្រុកៗវិញ ។

វិសាល ៖ តាមផ្លូវមានរឿងអីកើតឡើងខ្លះទៅអ៊ំ?

អ៊ូច ៖ តាមផ្លូវឃើញទ័ពវៀតណាមដែរសេដ្ឋកិច្ចរបស់វាដឹកគ្រាប់កាំភ្លើងអីនៅបន្តបន្ទាប់គ្នាពេញហ្នឹង ប៉ុនយើងស្លៀកពាក់ស៊ីវិលទៅអាខោអាវយើងដោះចោលអស់ទៅ យើងមកតែខ្លួនមក ។

វិសាល ៖ ខោអាវដោះស្លៀកពាក់ស៊ីវិល អញ្ចឹងបានន័យថាទាហានគេមានឯកសណ្ឋានគេ?

អ៊ូច ៖ ទាហានខោអាវខុសពណ៌ពីប្រជាជន ។

វិសាល ៖ ខុសពណ៌ខុសម៉េចទៅអ៊ំ?

អ៊ូច ៖ ពណ៌ខ្មៅពណ៌ខៀវតាមកង ។

វិសាល ៖ ចុះកងអ៊ំខោអាវខៀវ ឬក៏ខ្មៅ?

អ៊ូច ៖ ខោអាវខ្មៅ ។

វិសាល ៖ អូ ចហ្នឹងអ៊ំដូរបានខោអាវណាដូរ?

អ៊ូច ៖ ខោអាវប្រជាជនហ្នឹងសុំគាត់ស្លៀកពាក់មកហើយរបស់យើងចោលអស់ទៅ ។

វិសាល ៖ អូ បាទ តាមផ្លូវគេមានចាប់សួរចាប់អីទេ?

អ៊ូច ៖ អ្នកខ្លះគេមានសួរដែរហ្នឹង ។

វិសាល ៖ គេមានសួរអ៊ំទេ?

អ៊ូច ៖ អត់ខ្ញុំនៅតូចគេអត់ចាប់អារម្មណ៍សួរ ។

វិសាល ៖ តែ១៨ ១៩ អីហ្នឹង?

អ៊ូច ៖ អ៊ឺ

វិសាល ៖ បាទ អញ្ចឹងគេសួរអ៊ំដែរ តាមផ្លូវដើរប៉ុន្មានថ្ងៃបានមកដល់ផ្ទះវិញអ៊ំ?

អ៊ូច ៖ ពីរថ្ងៃ ។

វិសាល ៖ ពីរថ្ងៃ?

អ៊ូច ៖ បាទ!

វិសាល ៖ មកដល់ស្រុកភូមិហ្នឹងអ៊ំ?

អ៊ូច ៖ បាទស្រុកភូមិហ្នឹងវិញ ។

វិសាល ៖ កាលហ្នឹងមកឃើញឪពុកម្តាយទេ?

អ៊ូច ៖ អត់ទាន់ជួបម្តាយទេម្តាយរត់ទៅលើអត់ទាន់មក មកដល់ជួបបង ។

វិសាល ៖ បង?

អ៊ូច ៖ បងស្រីមានប្តីហើយហ្នឹង ។

វិសាល ៖ អូ គាត់នៅហ្នឹង?

អ៊ូច ៖ នៅហ្នឹង ។

វិសាល ៖ អញ្ចឹងរស់នៅហ្នឹងសិន ហើយកាលណាបានអ៊ំស្រីមកវិញ?

អ៊ូច ៖ យូដែរគាត់ទៅឯលើបានដាំងដប់ថ្ងៃបានមកដល់វិញ ។

វិសាល ៖ មកដល់វិញជុំគ្នាវិញទៅ?

អ៊ូច ៖ ដាច់ទឹកដាច់បាយដាច់ទឹកអត់មានបាយសេដ្ឋកិច្ចហូប ។

វិសាល ៖ អត់មានហូបទេ ពេលមកដល់វិញបានអង្ករបានអីឯណាដាក់ដាំទៅ?

អ៊ូច ៖ អង្ករស្រូវក្រុមរួមអាពតហ្នឹង ដល់ហើយបងប្អូនចេះតែចែករំលែកគ្នាកើបចែកគ្នាទៅអាកន្ទេនដាក់ស្រូវធំៗហ្នឹង ។

វិសាល ៖ អូ អាហ្នឹងកន្ទេនជង្រុកធំៗហ្នឹង?

អ៊ូច ៖ ហ្នឹងហើយជង្រុកធំៗហ្នឹង ។

វិសាល ៖ រួចយើងចកគ្នាហូបទៅ?

អ៊ូច ៖ បាទចែកគ្នាហូប នៅក្នុងភូមហ្នឹងកើបចែកគ្នាទៅចេះតែបុកចេះកិនអីហូបទៅ ។

វិសាល ៖ ហើយដល់ពេលជប់ថ្ងៃក្រោយមកបានលោកយាយមកវិញ?

អ៊ូច ៖ ដប់ថ្ងៃក្រោយមកមកវិញដល់នេះយើងរកកម្លាំងប្រជាជនឲ្យបានមូលធ្វើស្រែរួមគ្នាអញ្ចឹងទៅ ។

វិសាល ៖ ចុះបងប្អូនអីមកជាមួយលោកយាយដែរ?

អ៊ូច ៖ បងប្អូនៗមក ។

វិសាល ៖ មក គាត់កាលហ្នឹងនៅជុំគ្នា ឬក៏បែកគ្នា ឬក៏មកម្តងម្នាក់?

អ៊ូច ៖ មកជាមួយគ្នាមកជាមួយម្តាយគាត់រកគ្នាឃើញ ។

វិសាល ៖ គាត់និយាយប្រាប់ថាពេលដែលអ៊ំនៅឆ្ងាយនៅធ្វើកងចលិត ធ្វើទាហានមានដូចថានៅក្នុងភូមិមានរងទុក្ខវេទនាម៉េចខ្លះអីមាននិយាយទេ?

អ៊ូច ៖ ធ្លាប់ ហូបតែបបរ ។

វិសាល ៖ គាត់និយាយប្រាប់អញ្ចឹង?

អ៊ូច ៖ បាទ ហូបតែបបរទេមិនដែលបានបាយហូបទេហើយពេលហូបដួសចែករំលែកមួយចានម្នាក់ៗទេអត់បានហូបឆ្អែតល្អទេ វាជួបការលំបាកអញ្ចឹងណា ។

វិសាល ៖ ទោះបីជាគាត់ជាអ្នកមូលដ្ឋានក៏ដោយ?

អ៊ូច ៖ បាទ មូលដ្ឋានក៏ដោយថ្មី១៧ក៏ដោយគាត់ថាជួបការលំបាកច្រើនណាស់ ។

វិសាល ៖ ពេចូលមកវិញចូលមកក្នុងភូមិវិញអីហ្នឹងគឺថាបងប្អូនអីគឺរាប់អានយើងធម្មតា?

អ៊ូច ៖ រាប់អានទូទៅធម្មតា ស្រលាញ់គ្នាទៅវិញទៅមក ។

វិសាល ៖ អត់មានការរើសអើងអត់អីទេ?

អ៊ូច ៖ បាទ ។

វិសាល ៖ ខ្ញុំចង់សួរអ៊ុំបន្ថែម  អំបាញ់មិញភាគច្រើនទាក់ទងនឹងអ៊ីដែលអ៊ុំឆ្លងកាត់ផ្ទាល់ណែអ៊ីណែ ដល់ពេលចង់ជម្រាបសួរអ៊ុំអំពីរឿងតើអ៊ុំបានឃើញអត់  រឿងមួយចំនួនខ្ញុំចង់សុំសួរអ៊ុំខ្លះអ៊ុំណាទាក់ទងដូចជា  អ៊ុំមានបានឃើញដូចជាអំពើមនុស្សឃាត  ឬក៏ការសម្លាប់មនុស្សនៅសម័យខ្មែរក្រហមឃើញទេ?

អ៊ូច ៖ ខ្ញុំអត់បាននៅស្រុកអត់បាននៅស្រុកខ្ញុំចេញទៅទ័ពនោះ  អញ្ចឹងរឿងរ៉ាវនៅក្នុងភូមិអត់បានដឹងទេ  ប៉ុនតែម្ដាយនោះថាមានការលំបាកច្រើនធ្វើការ  ចាស់ៗអីដាំបន្លែដាំអីស្រោចទឹកស្រោចអីអញ្ចឹងទៅពេលភ្ជួរពេលអីយកមនុស្សទាញយកអី ដួបការលំបាកច្រើនណាស់ ។

វិសាល ៖ ទាក់ទងនឹងកងផលិតអ៊ុំអញ្ចឹងដែរ ឬក៏យ៉ាងម៉េច?

អ៊ូច ៖ អញ្ចឹងដែរអញ្ចឹងដូចគ្នា ។

វិសាល ៖ អត់គោទាញយកមុនុស្សទាញគ្នាដែរ?

អ៊ូច ៖ យកមនុស្សទាញគ្នាដែរជួបការលំបាកណាស់ ។

វិសាល ៖ ដល់ចុះដូចថាអំពើទារុណកម្មការធ្វើទារុណកម្មដាក់ទោស  លើអ្នកទោសក្ដីលើអ្នកធ្វើខុសក្ដីអ៊ុំដែលឃើញទេ?

អ៊ូច ៖ អត់ខ្ញុំអត់ដែលឃើញទេ ។

វិសាល ៖ អត់ដែលឃើញទេ?

អ៊ូច ៖ គ្រាន់តែដឹងថាប្រជាជនជួបការលំបាកគេអ្នកឃើញគេឃើញតែខ្ញុំអត់បានឃើញទេ ។

វិសាល ៖ បាទៗ  ដូចទាក់ទងនឹងការបំភ្លេចបំផ្លាញធ្វើទុកបុកម្នេញខាងសាសនា  ដូចជាការដូចថាការបង្ខិផ្សឹកលោកអីអញ្ចឹង ការវ៉ៃវិហារចោលអីអញ្ចឹងមានដែលឃើញទេអ៊ុំ?

អ៊ូច ៖ អត់ ។

វិសាល ៖ អត់ដែលទេ?

អ៊ូច ៖ ប៉ុនតែគ្រាន់តែខ្ញុំមកក៏ឃើញគេវ៉ៃចោលសាលាអីអស់ដែរ  វ៉ៃតាំងពីរបងវិហារវ៉ៃខ្ទេចខ្ទីអស់ ។

វិសាល ៖ ឃើញហ្នឹងឃើញពេល?

អ៊ូច ៖ ឃើញពេលគេវ៉ៃហើយហ្នឹង ។

វិសាល ៖ ឃើញពេលវ៉ៃហើយអត់ឃើញពេលកំពង់វ៉ៃទេ?

អ៊ូច ៖ ឃើញវ៉ៃហើយ ។

វិសាល ៖ បាទ ចុះពេលគេការងីអ៊ុំមានដែលឃើញគេការទេ?

អ៊ូច ៖ កាលនោះខ្ញុំអត់ទាន់ដឹងក្ដីទេតែឃើញគេការប្ដេជ្ញានៅអាពតហ្នឹងម្ដងបួនដប់គូៗ អញ្ចឹង ទៅណា ។

វិសាល ៖ ឃើញដែរ?

អ៊ូច ៖ ឃើញដល់ពេលរៀបចំមេកងគេហៅអញ្ចឹងទៅ ហកខាងនារីគេហៅគ្នាគេមកប៉ុនមិនដឹងអ្នកណាស្រលាញ់អ្នកណាទេគឺចាប់បង្ខំការជាគូអញ្ចឹងទៅ ។

វិសាល ៖ ហេតុការហ្នឹងកើតឡើងនៅកន្លែងណាទៅអ៊ំ?

អ៊ូច ៖ នៅកន្លែងអ៊ីដូចថាកន្លែងស្នាក់ការគេអញ្ចឹងណា ។

វិសាល ៖ កាលហ្នឹងអោងនៅក្នុងកងផលិត ឬក៏?

អ៊ូច ៖ ខ្ញុំនៅក្នុងកងផលិត ។

វិសាល ៖ នៅក្នុងកងផលិតនៅភូមិនៅឃុំអង្គប្រាសាទ ភូមិរលាបត្នោតគឺឃើហេតុការណ៍នៃការបង្ខំឲ្យរៀបការ?

អ៊ូច ៖ បង្ខំឲ្យរៀបការ ។

វិសាល ៖ កាលហ្នុងអ៊ំធ្វើការនៅជិតកន្លែងគេរៀបការហ្នឹងហ្នុងហ្នបានឃើញ?

អ៊ូច ៖ កាលហ្នុងចាស់ៗរើសចេញពីកងខ្ញុំហ្នុងយកទៅផ្សំផ្គុំហ្នឹង ។

វិសាល ៖ ចាស់ៗប្រហែលអាយុប៉ុន្មានទៅអ៊ំ?

អ៊ូច ៖ អាយុបហែលជាសាមជាង ។

វិសាល ៖ ក៏មានដែរ?

អ៊ូច ៖ ក៏មានដែរ ។

វិសាល ៖ ម្ភៃជាងអីហ្នឹង?

អ៊ូច ៖ បាទ ម្ភៃជាងមិនទាន់ទេសាមជាង ។

វិសាល ៖ សូមទោសអ៊ំកាលហ្នឹងមើលទៅដឹងថាគាត់ហ្នឹងអ្នកមានគ្រួសារហើយ ឬក៏អ្នកហ្នឹងនៅក្រមុំកម្លោះទេ?

អ៊ូច ៖ សុទ្ធតែក្រមុំកម្លោះសុទ្ធតែនៅលីវទាំងអស់ ។

វិសាល ៖ តែម្ភៃសាមសិបឆ្នាំ?

អ៊ូច ៖ បាទ សុទ្ធតែនៅលីវ ។

វិសាល ៖ ស្គាល់ចាំអាចចាំឈ្មោះគាត់ខ្លះទេ?

អ៊ូច ៖ អត់បែកគ្នាអស់ហើយ ។

វិសាល ៖ បាទៗ កាលហ្នឹងឃើញហ្នឹងឃើងហេតុការណ៍យ៉ាងម៉េចខ្លះទៅអ៊ំ?

អ៊ូច ៖ ការហ្នឹងរៀបចំដូចប្រមូលផ្ដុំអញ្ចឹងទៅដូចថាម្ដងដប់ប្រាំម្ដងដប់គូអីអញ្ចឹងទៅណា នារីដប់ យើងដប់អញ្ចឹងទៅបុរស់ហ្នឹងដប់នារីដប់អញ្ចឹងទៅ ។

វិសាល ៖ ហើយម៉េចទៅ?

អ៊ូច ៖ ដល់ហើយយកទៅផ្ដាច់ជាគ្រាន់តែសុំស្គាល់គ្នា ទទួលស្គាល់គ្នាជាប្ដីប្រពន្ធអញ្ចឹងទៅគេ ឧបកិច្ចឲ្យអញ្ចឹងទៅ ម្ដងៗប្រាំបួនដប់គូអញ្ចឹងទៅ ។

វិសាល ៖ គេមានដូចជាពិធីជប់លៀងអីទេ ឬក៏អត់ទេ?

អ៊ូច ៖ ធ្វើកម្មវិធីដែរហ្នឹងកម្មវិធីដូចជាកាប់មាន់កាប់អីធ្វើកម្មវិធីជប់លៀងកន្លែងការហ្នឹងទៅណា ។

វិសាល ៖ តែគេឲ្យតែអ្នកការទេ ឬក៏អ្នកផ្សេង?

អ៊ូច ៖ ឲ្យតែអ្នកការហ្នឹងហូប ។

វិសាល ៖ មិនមែនឲ្យអ៊ំហូបទេ?

អ៊ូច ៖ អ្នកអត់ទៅអត់ឲ្យហូបទេឲ្យតែអ្នកសមីខ្លួនគេ ។

វិសាល ៖ ហើយនឹងមេៗ?

អ៊ូច ៖ ហើយនឹងអ្នកដែលផ្សំផ្គុំឲ្យហ្នឹង ។

វិសាល ៖ មានច្រៀងរាំមានអីទេ?

អ៊ូច ៖ អត់ៗ ។

វិសាល ៖ អត់ទេបាទៗ អ៊ំៗមានប្រសាសន៍ថាគេឡើងផ្ដាច់ជានោះអ៊ំកាលហ្នឹងឃើញម៉េចទៅពេលគេ ឡើងផ្ដាច់ជា?

អ៊ូច ៖ ផ្ដាច់ជាថាទទួលស្គាល់គ្នាជាប្ដីប្រពន្ធអញ្ចឹងទៅមួយគូៗម្នាក់អញ្ចឹងទៅ ។

វិសាល ៖ ដល់ពេលឡើងផ្ដាច់ជាគេធ្វើម៉េចទៅ?

អ៊ូច ៖ ផ្ដាច់ជាថាយើងស្រលាញ់អ្នកនេះអញ្ចឹងទៅណា ស្រលាញ់បុរសនេះប៉ុន្តែក្នុងចិត្តគ្នាមិន ស្រលាញ់ទេព្រោះតែគេបង្ខំឲ្យយើងធ្វើ ការហើយបើមិនស្រលាញ់ក៏គេមិននេះយើងដែរ គេមិនទុកយើងដែរ ។

វិសាល ៖ មានអ្នកការហ្នឹងដែលនៅធ្វើការក្នុងកងអ៊ំមានទេ មានដូចថាប្រុសៗណាអ៊ំនៅក្នុងកងប្រុស ត្រូវទេអ៊ំ?

អ៊ូច ៖ បាទ!

វិសាល ៖ ហើយអញ្ចឹងមានស្គាល់ឲ្យគេចាត់ឲ្យការហ្នឹងទេ?

អ៊ូច ៖ អាហ្នឹងមេកងគេអត់ស្គាល់ ។

វិសាល ៖ អ្នកដែលត្រូវគេបន្ទុំឲ្យការដែលធ្វើការជាមួយអ៊ំស្គាល់ឈ្មោះគេទេ?

អ៊ូច ៖ អត់ៗទេ ។

វិសាល ៖ អូ អ៊ំតាមការសង្កេតឃើញរបស់អ៊ំៗណា ចង់សួរថាពួកគាត់ហ្នឹងស្គាល់អ្នកខាងស្រីហ្នឹងទេ ឬក៏អត់ស្គាល់ទេ?

អ៊ូច ៖ អត់ស្គាល់ទេមនុស្សអត់ដែលឃើញគ្នាផង ។

វិសាល ៖ ចុះពេលធ្វើការហ្នឹងមិនមែនដើរកាត់មុខគ្នាទេ?

អ៊ូច ៖ អត់ទេអត់ដើរកាត់មុខគ្នាទេដូចជាថាមួយកងនៅឯវត្តភ្នំនោះ បុរសនៅនេះនារីនៅនោះ ទៅអត់ឲ្យអ្នកនៅក្បែរគ្នាទេ ។

វិសាល ៖ អូ គឺយកអ្នកនៅកងផ្សេងគ្នាហ្មង អត់ឲ្យឃើញគ្នាទេ?

អ៊ូច ៖ បាទ!

វិសាល ៖ អូ ហើយហេតុការហ្នឹងអ៊ំឃើញ?

អ៊ូច ៖ ឃើញខ្ញុំនៅកន្លែងកង នៅកន្លែងស្មងការគេហ្នឹង ។

វិសាល ៖ បាទៗ ចុះទាក់ទងនឹងការបង្អត់អាហារអីមានទេអ៊ំមានទេ ការឲ្យអាហារហូបចុកមិនគ្រប់គ្រាន់អីអញ្ចឹងណានៅក្នុងសហករណ៍?

អ៊ូច ៖ មាន ។

វិសាល ៖ មានដែរ?

អ៊ូច ៖ បាទ មានហូបមិនដិដល់ ។

វិសាល ៖ ហូបមិនដិតដល់ កាលហ្នឹងនៅណាទៅហូបមិនដិដល់?

អ៊ូច ៖ អ៊ឺ ពិសេសដូចជាម្ដាយខ្ញុំអីហ្នឹងគាត់ហូបមិនដិតដល់ទេ ព្រោះកាលហ្នឹងគាត់ជួបការលំបាកច្រើនហើយគាត់ចាស់ ដូចថាដាំបន្លែដាំអីមែនតែស្រេចលើចុងកៅគេដាក់កំរិតហ្មងគឺមិនដិតដល់ទេ បានដំឡូងបានអីចេះតែស្ងោរហូបនៅផ្ទះទៅ ។

វិសាល ៖ ពេលជួបគ្នាគាត់ប្រាប់អ៊ំទេអ៊ំណែ ព្រោះអ៊ំអត់នៅជាមួយគាត់ទេ?

អ៊ូច ៖ គាត់ប្រាប់ ខ្ញុំមិនបាននៅជាមួយគាត់ទេព្រោះខ្ញុំនៅឯណាណីនោះ ។

វិសាល ៖ ចុះទាក់ទងពីការដាក់គុកដាក់អីមានទេអ៊ំ និយាយពីគុកវិញ?

អ៊ូច ៖ អ៊ឺ ខ្ញុំឮគេថាដែរប៉ុន្តែខ្ញុំមិនដែលឃើញ ។

វិសាល ៖ អត់ដែលឃើញទេ?

អ៊ូច ៖ បាទ ពុតែគេថា ។

វិសាល ៖ ចុះអញ្ចេះចង់សួរពីការចាប់រំលោភស្រ្តីភេទនៅសម័យខ្មែរក្រហម ដែលឃើញដែលជួបប្រទះទេ?

អ៊ូច ៖ អត់ៗ ។

វិសាល ៖ អត់ដែលបានពុទេ?

អ៊ូច ៖ អត់ អូ ជំនាន់ហ្នឹងតែហ៊ានរំលោភសិទ្ធលើនារីបុរសអីសុទ្ធតែយកទៅវៃចោលទាំងអស់ ។

វិសាល ៖ អូ វៃចោលតែម្តង?

អ៊ូច ៖ វៃចោលអត់មានទុកមុខទេ ។

វិសាល ៖ ចង់ជំរាបសួរអ៊ំៗការបង្ខំឲ្យក្មេងៗធ្វើការវិញដែលជួបប្រទះទេ? ក្មេងៗប្អូនដប់ឆ្នាំអីដែលធ្វើការមើលទៅក្មេងហ្នឹងមិនសមនឹងធ្វើការទេតែគេឲ្យធ្វើការ កាលហ្នឹងមានទេអ៊ំ?

អ៊ូច ៖ បាទ អ៊ីមួយគឺមានកងកុមារ កងកុមារហ្នឹងកុមារសិក្សាតូចៗហ្នឹងប្រមូលផ្តុំទុកមួយដុំទៅយកកម្លាំងប្រើអញ្ចឹងទៅដូចថា ជួនកាលរែកដីដឹបូកជួនកាលបោចស្មៅស្រូវអញ្ចឹងអីមានដែរតែគេមានគ្រូគេនាំទៅ ។

វិសាល ៖ អ៊ំកាលហ្នឹងក្មេងៗគេឲ្យធ្វើការដែលសមនឹងអាយុគេទេ ឬក៏ឲ្យមសមនឹងអាយុគេទេ?

អ៊ូច ៖ ធ្វើការស្រាលដែរបើបង្ខំឲ្យរែកប្រឡាយលើកទំនប់អីអត់ទេ ។

វិសាល ៖ ស្រាលដែរ?

អ៊ូច ៖ បាទ បោចស្មៅអីហ្នឹង ។

វិសាល ៖ បាទៗ អញ្ចឹងខ្ញុំសូមត្រលប់ទៅរឿងខាងក្រោយបន្តិចអ៊ំណា គឺនៅមន្ទីរបេទ្យនៅក្បាលដំរីដែលអ៊ំបានឃើញមនុស្សស្លាប់ច្រើននៅទីនោះអញ្ចឹងអ៊ំណា អ៊ំមានប្រសាសន៍អញ្ចឹងពេលនោះអ៊ំមានជម្ងឺគ្រុនចាញ់ហើយអ៊ំបានទៅដេកសម្រាកនៅពេទ្យក្បាលដំរីហ្នឹង?

អ៊ូច ៖ បាទ

វិសាល ៖ ពេទ្យក្បាលដំរីហ្នឹងមើលទៅប៉ុណ្ណាដែរទៅអ៊ំ?

អ៊ូច ៖ ពេទ្យហ្នឹងធ្វើពីរខ្នងបណ្តោយប្រហែលដប់ម៉ែត្រទទឹងប្រហែលប្រាំមួយម៉ែត្រ ។

វិសាល ៖ ប្រាំមួយម៉ែត្រពីរខ្នង?

អ៊ូច ៖ បាទ!

វិសាល ៖ ការទៅសម្រាកនៅហ្នុងសម្រាកពេទ្យប៉ុន្មានថ្ងៃដែរទៅអ៊ំមានចាំទេ?

អ៊ូច ៖ ទៅនៅដប់ថ្ងៃខ្ញុំទម្រាំជម្ងឺហ្នឹងជាៗ ។

វិសាល ៖ អញ្ចឹងអ្នកស្រុកអ្នកភូមិម្ដាយអីក៏អត់ដឹងដែរ?

អ៊ូច ៖ អត់ដឹងដាច់ធ្វើការទាក់ទងគ្នាអត់បានដាច់ខ្សែរយៈ ។

វិសាល ៖ បាទ កាលហ្នឹងគេបញ្ជូនអ៊ំទៅពីកងផលិតនោះទៅ?

អ៊ូច ៖ បាទ!

វិសាល ៖ កាលហ្នឹងអ៊ំឈឺខ្លាំងអ៊ំហ្នឹងបានគេបញ្ជូនទៅ?

អ៊ូច ៖ គ្រុនចាញ់គ្រុនមានពេលកាលហ្នឹងគ្រុនដូចថាម៉ោងពីរអញ្ចឹងញាក់ដឹងថាម៉ោងពីរពីរដាងញាក់ពីរពីរដាងញាក់ៗរាល់តែថ្ងៃ ។

វិសាល ៖ មេកងអ៊ំបញ្ជូនអ៊ំទៅ?

អ៊ូច ៖ បាទ ដល់ហើយប្រធានកងគេបញ្ជូនទៅ ។

វិសាល ៖ មិនមែនតា សង ណាអ៊ំ ឬមួយក៏តាសង ហ្នឹងហើយ?

អ៊ូច ៖ បាទ តាសង ហ្នឹង ។

វិសាល ៖ បញ្ជូបអ៊ំទៅដាក់អីទៅ?

អ៊ូច ៖ រទេះសេះ ។

វិសាល ៖ រទេះសេះទៅបញ្ជូនអ៊ំទៅ ទៅដល់ពេទ្យហ្នឹងតាមការសង្កេតឃើញបុគ្គលិកពេទ្យហ្នឹងមានច្រើនទេអ៊ំ?

អ៊ូច ៖ ច្រើនដែរប៉ុនច្រើនតែនារីៗ ។

វិសាល ៖ បាទៗ ប្រហែលប៉ុន្មាននាក់ដែរទៅមានចាំទេ?

អ៊ូច ៖ ប្រហែលដាងដប់នាក់ ។

វិសាល ៖ ដាងដប់នាក់ នារីៗហ្នឹងមើលទៅគាត់ក្មេងៗ ឬក៏ចាស់គួសមដែរ?

អ៊ូច ៖ មានក្មេងមានចាស់ ។

វិសាល ៖ មានក្មេងមានចាស់ទៀត? មានក្មេងមានចាស់ហើយគ្រែអីមានប៉ុន្មានទៅ?

អ៊ូច ៖ គ្រែតាមបន្ទប់មួយបន្ទប់បួនប្រាំៗអញ្ចឹងទៅ បន្ទប់គ្រែមួយម្នាក់ៗអញ្ចឹងទៅ ។

វិសាល ៖ អ៊ំសម្រានលើគ្រែដែរទៅ?

អ៊ូច ៖ លើគ្រែ ។

វិសាល ៖ មានព្យួរសេរ៉ូមមានអីទេអ៊ំ?

អ៊ូច ៖ អត់មានទេអត់ដាក់សេរ៉ូមទេដឹងតែចាក់ហ្មង ។

វិសាល ៖ ចាក់តែម្ជុល ចាំហ្នឹងគេចាក់ដឹងពេលដែរ ឬក៏ចេះតែចាក់?

អ៊ូច ៖ ចាក់ពេលប្រហែលជាម៉ោងប្រាំបីប្រាំបួនចាក់ ឲ្យមួយថ្ងៃមួយម្ជុល ៗ ។

វិសាល ៖ បាទ មួយថ្ងៃចាក់តែមួយម្ជុលទេ?

អ៊ូច ៖ បាទ ។

វិសាល ៖ ហើយក្រៅពីហ្នឹងមានលេបថ្នាំលេបអីទេ?

អ៊ូច ៖ លេប ៗ ថ្នាំប៉ុនថ្នាំដូចអាចទន្សាយ ។

វិសាល ៖ ថ្នាំអាចទន្សាយ?

អ៊ូច ៖ បាទ ថ្នាំដូចមេស្រាមីបន្តិចអីបន្តិចល៊ីង ៗ អញ្ចឹង ។

វិសាល ៖ អញ្ចឹងមួយថ្ងៃតាមអ៊ំមានប្រសាសន៍មិញគឺមួយម្ជុល ក្រៅពីហ្នឹងថ្នាំអាចទន្សាយ?

អ៊ូច ៖ បាទ!

វិសាល ៖ រាល់ថ្ងៃ?

អ៊ូច ៖ រាល់ថ្ងៃ ។

វិសាល ៖ ហើយដល់ពេលអ្នកជម្ងឺអញ្ចឹគេឲ្យអីហូប?

អ៊ូច ៖ ជីវភាពបាយដំនាំធម្មតាហើយសម្ល៉ក៏អត់ទៀងដែរជួនកាលសម្លត្រកួនអញ្ចឹងទៅ ជួនកាលព្រលិតអញ្ចឹងទៅ ជួនកាលចេកអញ្ចឹងទៅ ។

វិសាល ៖ ហូបមួយថ្ងៃប៉ុន្មានពេលដែរអ្នកជម្ងឺ?

អ៊ូច ៖ មួយថ្ងៃហូបពីរពេល ។

វិសាល ៖ ព្រឹកមានទេ?

អ៊ូច ៖ ព្រឹកអត់មានទេប្រហែលជាម៉ោងដប់បានហូប លៃថ្ងៃល្ងាចម៉ោងប្រាំបានហូប ។

វិសាល ៖ ហើយយើងនៅសម្រាកសម្រានលើគ្រែហ្នឹងទៅ?

អ៊ូច ៖ នៅលើគ្រែហ្នឹងអត់ប្រើអីទេ ។

វិសាល ៖ ហើយការមើលថែទាំអ្នកជម្ងឺពីសំណាក់ពេទ្យនារីនៅកន្លែងហ្នឹងមានលក្ខណៈជិតដល់ដូចថាគាត់មើលទៅយកចិត្តទុកដាក់ចំពោះអ៊ំទេការថែទាំហ្នឹងអ៊ំ?

អ៊ូច ៖ អាស្រ័យលើជម្ងឺប៉ុនបើជម្ងឺយើងស្រាលគេមិនសូវយកចិត្តទុកដាក់ បើជម្ងឺគេធ្ងន់ហ្នឹងគេអាចដូចថាមើលថែឲ្យជិតដល់ញឹកដែរ ។

វិសាល ៖ ញឹកដែរ កាលករណីអ៊ំញឹកទេ?

អ៊ូច ៖ អត់ទេ ។

វិសាល ៖ កាលហ្នឹងអ៊ំអត់សូវឈឺធ្ងន់ទេ?

អ៊ូច ៖ បាទ គ្រុនហ្នឹងវាអាចលទ្ធភាពជម្ងឺវាស្រាល ។

វិសាល ៖ ស្រាលបាទៗ នៅទីនោះអ៊ំមានប្រសាសន៍ថាឃើញមនុស្សស្លាប់ច្រើន ស្លាប់ច្រើនហ្នឹងគាត់ស្លាប់ដោយសារមូលហេតុអីដែរទៅអ៊ំបើតាមការសង្កេតឃើញរបស់អ៊ំ?

អ៊ូច ៖ ដូចវាមើលជម្ងឺហ្នឹងមិនត្រូវដូចវាមិនស៊ីនឹងជាតិថ្នាំ ថ្នាំហ្នឹងដូចថាវាមិនអាចសម្លាប់ជម្ងឺហ្នឹងបានដល់អញ្ចឹងហើយគេចេះតែុកឲ្យស្លាប់អញ្ចឹងទៅបើវ៉ែថ្នាំវាមិនត្រូវ ។

វិសាល ៖ វ៉ែថ្នាំមិនត្រូវ បាទៗ គាត់កាលហ្នឹងឈឺហ្នឹងត្រូវរបួស ឬក៏ឈឺជម្ងឺអី ឬក៏?

អ៊ូច ៖ គ្រុនចាញ់អញ្ចឹងទៅដូចថាជម្ងឺផ្សេងៗដូចថាជម្ងឺចុកពោះចុកអីអញ្ចឹងទៅ ជួនកាលអាគ្រុនចាញ់ថ្នាំវ៉ែអត់ត្រូវក្តៅខ្លាំងពេកអញ្ចឹងទៅក្តៅៗរហូតដល់ស្លាប់អញ្ចឹងទៅក៏មាន ។

វិសាល ៖ បាទៗ អ៊ំនៅសម្រាកហ្នឹងមានឃើញអ្នកនៅជិតអ៊ំនេះ អ្នកជម្ងឺសុខៗក៏ស្លាប់អីអញ្ចឹងមានទេ?

អ៊ូច ៖ នៅបន្ទប់ខ្ញុំអត់មានទេប៉ុន្តែបន្ទប់ជាប់ខ្ញុំមាន ។

វិសាល ៖ ឮគេនិយាយឬក៏បានឃើញ?

អ៊ូច ៖ បាទ គេថាស្លាប់ដោយសារនៅៗក្តៅពេកទៅស្លាប់ក៏ស្លាប់បាត់ទៅផញ្ចឹងទៅ អត់មានថ្នាំអីវ៉ែជម្ងឺហ្នឹងត្រូវ ។

វិសាល ៖ កាលនៅហ្នឹងជាងដប់ថ្ងៃមានឮចាំបានទេថាមួយថ្ងៃស្លាប់ប្រហែលប៉ុន្មាននាក់ដែរ?

អ៊ូច ៖ មិនទៀងអត់ដឹងដែរកាលខ្ញុំទៅដប់ថ្ងៃស្លាប់ពីរបីនាក់ទេ ។

វិសាល ៖ ពីរបីនាក់ទេ?

អ៊ូច ៖ បាទ គាត់ស្លាប់ហ្នឹងដោយសារជម្ងឺចាស់ទេហើយដល់ចុកៗមើលមិនត្រូវអញ្ចឹងទៅ គាត់ស្រែកទាល់តែដាច់ខ្យល់អញ្ចឹងទៅ ។

វិសាល ៖ ស្រែកទាល់តែដាច់ខ្យល់ ឮសម្លេងគាត់ស្រែក?

អ៊ូច ៖ គាត់ស្រែកថាចុកណាស់ៗ ដឹងធ្វើម៉េចបើថ្នាំវាយមិនត្រូវ ។

វិសាល ៖ បាទ ហើយគាត់ក៏ស្លាប់ទៅ?

អ៊ូច ៖ បាទ ហើយបើអាក្តៅអត់មានមូលហេតុហ្នឹងក្តៅៗទាល់តែដាក់ថ្នាំស្អីក៏មិត្រូវស្អីក៏មិនត្រូវដល់តែសន្លប់ស្លាប់អញ្ចឹងដែរទៅ ។

វិសាល ៖ បាទៗ ង៊ឺ នៅទីនោះមានស្គាល់មេពេទ្យនៅនោះទេ?

អ៊ូច ៖ អត់ៗស្គាល់គេទេ ។

វិសាល ៖ អត់ស្គាល់ទេ?

អ៊ូច ៖ ព្រោះយើងទៅដេកងាវយៈពេលខ្ញីពេកអត់ស្គាល់ទេ ។

វិសាល ៖ អ្នកជម្ងឺចេញចូរច្រើនទេអុំ?

អ៊ូច ៖ ចេញចូលច្រើនដែរ ។

វិសាល ៖ តែមិនមែនទាហានទេអុំណែ?

អ៊ូច ៖ អត់ទេ ។

វិសាល ៖ តែប្រជាជនធម្មតាទេ?

អ៊ូច ៖ បាទ តែប្រជាជនធម្មតា ។

វិសាល ៖ គន្ធីមានអីចង់សួរអុំទេ?

គន្ធី ៖ ចាំ! អ៊ុ អុំខ្ញុំចង់សួរបកពេលអុំទៅធ្វើទាហានណា អុំចូលធ្វើឆ្នាំ៧៧ ៧៨អញ្ចឹងអុំណែ?

អ៊ូច ៖ ហ្នឹងហើយ ។

គន្ធី ៖ ចាំ អុំអ៊ឺដូចថាដល់ពេលអ៊ឺ ខាងមេកងសងអញ្ចឹងអុំណែ?

អ៊ូច ៖ បាទ នៅកងផលិត ។

គន្ធី ៖ ចាំ នាំអុំអញ្ចឹងទៅហេតុអីបានគេនាំអុំទៅធ្វើទ័ពទេ?

អ៊ូច ៖ គ្រាន់តែប្រាប់ថាយកទៅធ្វើទ័ពអញ្ចឹងហ្នង ។

គន្ធី ៖ កងទ័ព គេមានថាយកអុំហ្នឹងដូចថាយកទៅកងទ័ពហ្នឹងដូចថាវៃជាមួយពីណា របៀបដូចថាអ៊ឺ ដូចថារើទៅភ្លាមៗអញ្ចឹងយកទៅអ៊ឺ អុំវៃជាមួយច្បាំងជាមួយច្បាំងជាមួយ ឬត្រូវធ្វើការងារហ្នឹងភ្លាមៗ ឬដូចថាជាបន្ទាន់ឬក៏ជាការរើសធម្មតានៅក្នុងភូមិហ្នឹង?

អ៊ូច ៖ ជ្រើសហ្នឹងជ្រើសតាមកម្លាំងហ្នឹងគេដូចថាយកកុមារទៅពេញវ័យគេអាចដូចថា គេស្រណុក បំពាក់បំប៉នដល់ហើយទៅកងទ័ពហ្នឹងគេប្រាប់ថាទៅធ្វើទ័ពអញ្ចឹងហ្នង ។

គន្ធី ៖ ប្រាប់ថាទ័ពអត់មានថាយកទៅវៃជាមួយពីណាអីអត់ទេ?

អ៊ូច ៖ ទៅវៃជាមួយវៀតណាម ។

គន្ធី ៖ វៀតណាម ហើយកាលហ្នឹងគាត់មានប្រាប់ថាពេលហ្នឹងមានរឿងអីជាមួយវៀតណាមទេអុំ?

អ៊ូច ៖ ថាវៀតណាមឈ្លានពានដីយើង ។

វិសាល ៖ គេនិយាយអញ្ចឹងហ្នងអុំណែ?

អ៊ូច ៖ បាទ គេថាវៀតណាមឈ្លានពានដីយើង យើងយកកម្លាំងទៅទប់ ។

គន្ធី ៖ យកកម្លាំងទៅទប់ហើយកាលហ្នឹងអ៊ី ការើសរបស់មេកងសងហ្នឹង អ៊ំពេញចិត្តធ្វើទាហានហ្នឹងផ្ទាល់ ឬក៏យ៉ាងម៉េចដែរ?

អ៊ូច ៖ បើថាយើងមិនពេញចិត្តក៏គេត្រូវឲ្យទៅដែរព្រោះគេបង្ខិតបង្ខំឲ្យទៅហើយ ។

គន្ធី ៖ អារម្មណ៍អ៊ំយ៉ាងម៉េចដែរអ៊ំ?

អ៊ូច ៖ អារម្មណ៍ខ្លាចគេព្រោះកាលហ្នឹងប៉ុលពតបើយើងមិនទៅក៏គេវ៉ៃយើងចោលដែរ ដល់អញ្ចឹងចេះតែទៅៗ ។

គន្ធី ៖ អញ្ចឹងមានន័យថាអ៊ំអត់ពេញចិត្តទេ?

អ៊ូច ៖ មានន័យថាមិនទៅមិនបានបើឲ្យទៅណាត្រូវតែទៅហ្នឹង ។

គន្ធី ៖ ដាច់ខាតអញ្ចឹងហ្នង?

អ៊ូច ៖ ដាច់ខាតគឺអញ្ចឹង ។

គន្ធី ៖ អញ្ចឹងអ៊ំដល់ពេលធ្វើទាហានអញ្ចឹង ដូចថាកាលហ្នឹងអ៊ំគិតថាវាជាការរើសប្រញាប់ ឬក៏រើសធម្មតាក្នុងភូមិគ្រាន់តែគេត្រូវ ឬយ៉ាងម៉េចអ៊ំ?

អ៊ូច ៖ រើសហ្នឹងរើប្រញាប់ហ្នងរើសយកទៅវ៉ាវហ្នងថាតែទៅៗហ្នង មិនមែនថាអ្នកឯងទៅដោយស្ម័គ្រចិត្តអីអត់ទេដូចថាបើឲ្យទៅមិនទៅក៏បានអត់ទេ ថាទៅគឺទៅអញ្ចឹងតែម្តង ។

គន្ធី ៖ ជាការប្រញាប់?

អ៊ូច ៖ ជាការប្រញាប់ហ្នង ។

គន្ធី ៖ ហើយពេលអ៊ំទៅហ្នឹងតាមវិសាលសួរថាអ៊ំអ៊ុំ បានហ្វឹកហាត់តែកន្លះខែទេមែនទេ?

អ៊ូច ៖ ហ្នឹងហើយតែកន្លះតែទេ ។

គន្ធី ៖ អ៊ំជឿជាក់ថាខ្លួនឯងហ្នឹងអាចតស៊ូជាមួយវៀតណាមទេ?

អ៊ូច ៖ ជឿជាក់ហ្នឹងយើងគិតថាធ្វើម៉េចបើកើតមកត្រូវប្រទេសកើតសង្គ្រាមហើយ គេត្រូវការហើយយើងត្រូវតែទៅគេតម្រូវហើយ រស់ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ហ្នឹងធ្វើម៉េចត្រូវតែទៅអញ្ចឹងហ្នងព្រោះយើងមិនទៅក៏មិនបាន បើគេបង្ខិតបង្ខំហើយ ។

គន្ធី ៖ ចុះអ៊ំគិតថាពេលហ្នឹងមានប្រជាជនថ្មីដែលគេជម្លៀសមកពីតំបន់ផ្សេងៗគេបង្ខំទៅធ្វើទ័ពទេអ៊ំ?

អ៊ូច ៖ ចម្រុះគ្នាហ្នង ។

គន្ធី ៖ អញ្ចឹងមិនថាតែពួកមូលដ្ឋាន?

អ៊ូច ៖ មិនថាតែពួកខ្ញុំទេគ្រប់ខេត្តគ្រប់ទូទាំងប្រទេសអញ្ចឹងទាំងអស់ ។

គន្ធី ៖ ចាំ ប៉ុន្តែកាលហ្នឹងជាដូចថាជាអ្នកមូលដ្ឋាន ឬក៏ជាអ្នកមកថ្មីដែលគេរើសទៅជាមួយគ្នាហ្នឹង?

អ៊ួច ៖ អ៊ឺ មូលដ្ឋានៗហ្នឹងគេយកដល់តែអ្នកថ្មីគេអត់យកទេ ។

គន្ធី ៖ ម៉េចអញ្ចឹងអ៊ំ?

អ៊ួច ៖ ដឹងទេគេរើសកាលហ្នឹងវាមានពួកគេហៅពួក១៧ហ្នឹងអី ។

វិសាល ៖ អញ្ចឹងទៅកងផលិតហ្នឹងសុទ្ធតែអ្នកមូលដ្ឋានទេ ឬក៏មានអ្នកថ្មីដែរ?

អ៊ួច ៖ អាហ្នឹងអ៊ឺ អត់ទេពួកថ្មីដែរទៅហ្នឹងទៅលាយឡំគ្នានៅជាមួយគ្នាទាំងអស់ ។

វិសាល ៖ បាទ!

គន្ធី ៖ តែអ៊ំដល់ពេលរើសធ្វើទាហានហ្នឹងគេរើសតែ?

អ៊ួច ៖ រើសតែពួកចាស់ទេ ។

គន្ធី ៖ ពួកចាស់ទេ?

អ៊ួច ៖ ពួកចាស់មូលដ្ឋាន ។

វិសាល ៖ មានដឹងមូលហេតុទេ?

អ៊ួច ៖ អត់ដឹងមិនដឹងគេបែងចែកវណ្ណៈយ៉ាងម៉េចអត់ដឹង អត់ដឹងពួកអាពតអត់ដឹងថា បែកចែកវណ្ណៈម៉េចដែរគ្រាន់តែគេថាយកពួកមូលដ្ឋានទៅពួកថ្មីអត់ឲ្យទៅ ។

គន្ធី ៖ អញ្ចឹងក្នុងកងអ៊ំហ្នឹងមានផ្នែកមូលដ្ឋានមានអ្នកថ្មី ហើយគេរើសតែអ្នកចាស់ទេទៅធ្វើទាហាន?

អ៊ួច ៖ ហ្នឹងហើយ ។

គន្ធី ៖ ហើយអ៊ឺ អញ្ចឹងក្នុងការពេលអ៊ំរស់នៅធ្វើការជាមួយគ្នាជាមួយអ្នកថ្មីហ្នឹង ដូចថាអ៊ំមានឃើញដូចថាការគ្រប់គ្រងបែកចែកដូចថាឲ្យមាន គេមានចេតនាមួយ ឬក៏យ៉ាងម៉េចដែរអ៊ំជាមួយអ្នកចាស់នឹងអ្នកថ្មី?

អ៊ួច ៖ ធ្វើការហូបចុកជាមួយគ្នាដេកជាមួយគ្នាគ្រាន់តែពេលទៅធ្វើទ័ពអត់ឲ្យអ្នកថ្មីទៅតែប៉ុណ្ណឹង បើថាការហូបចុកពោលកម្មអីដូចគ្នាហូបចុកអីនឹងគ្នាដេកនឹងគ្នា នៅរួមរស់នឹងគ្នា ។

គន្ធី ៖ ចុះអ៊ំមនុស្សភាគច្រើនដែលចូលធ្វើទាហានដូចអ៊ំអញ្ចឹងដូចថា ធម្មតាបើសិនជាយើងនៅក្មេងយើងកាន់កាំភ្លើងអញ្ចឹងយើងសប្បាយនឹងកាន់កាំភ្លើង ឬមួយអ៊ំខ្លាចអីអញ្ចឹង?

អ៊ូច ៖ ក្នុងនាមជាអារម្មណ៍ខ្ញុំចង់ដែរហ្នឹងឆាប់អាណាមិនខ្លាចឆាប់ ប៉ុន្តែធ្វើម៉េចដើម្បីថាគេបង្ខិតបង្ខំអញ្ចឹងហើយបើឆាប់មនុស្សកំពុងពេញវ័យខ្លាចឆាប់ដូចតែគ្នា ប៉ុន្តែធ្វើម៉េចការគ្រោះថ្នាក់យើងមើលមិនឃើញការធ្វើសង្គ្រាម ។

គន្ធី ៖ ពេលនោះអ្នកដែលនៅក្នុងភូមិអីណាពេលអ្នកណាដែលគេជ្រើសរើសធ្វើទាហានអញ្ចឹង តើគេមានអារម្មណ៍យ៉ាងម៉េចដែរ ចំពោះដូចថាមានកូនចៅដូចជាអីអញ្ចឹងធ្វើទាហាន សប្បាយចិត្ត ឬក៏អត់សប្បាយចិត្ត?

អ៊ូច ៖ សប្បាយចិត្តអីបើគិតៗព្រួតែឆាប់ហ្នឹង កន្លែងសពនៅកណ្ដាលឃុំយើងនេះគ្រាន់តែសពកប់រាប់ពាន់ខ្មោចរួចអាសពកងទ័ពហ្នឹងណាកាលសង្គ្រាមជាមួយវៀតណាមហ្នឹង ឆាប់ទៅគេយកមកកប់ទុកហ្នឹងទឹកដីស្រុកគិរីវង្សយកមកកប់ទុកហ្នឹង ដល់តែកប់ទៅច្រើនកន្លែងពេកអញ្ចឹងធ្វើឡដុតបណ្ដោយចុះបើឆាប់ច្រើនពេក ។

វិសាល ៖ សាកសពខាងយើង ឬក៏ខាងគេ?

អ៊ូច ៖ ដាក់សព្វខាងខ្មែរក្រហម ។

វិសាល ៖ ខ្មែរក្រហម?

អ៊ូច ៖ បាទ កាលហ្នឹងហៅខ្មែរក្រហម ។

វិសាល ៖ បាទ ចង់សួរហ្នឹងព្រោះខ្លាចដាក់សព្វខាងវៀតណាមអី ។

អ៊ូច ៖ អត់ទេខាងខ្មែរយើង ។

គន្ធី ៖ ចុះពេលអីណាពេលប្រជុំទៅអញ្ចឹងអ៊ី ដូចថាពេលសង្គ្រាមជាមួយគ្នាហ្នឹងអីថាចាប់ផ្ដើមប្រយុទ្ធហើយអីថានៅឈរជើងក្រោយទេអីណែ?

អ៊ូច ៖ អ៊ឺ ខ្ញុំនៅតាមត្រង់សេហើយកម្លាំងគេនៅជួនកាលខាងមុខគេដកចេញមកខ្ញុំទៅនៅត្រៀមព្រំប្រទល់វៀតណាមម្ខាងយើងម្ខាងមាត់ព្រែកអញ្ចឹងទៅ ។

វិសាល ៖ អញ្ចឹងយើងបានបាញ់គ?

អ៊ូច ៖ បាញ់តទៅវិញទៅមកវាបាញ់យើងយើងបាញ់វា ។

គន្ធី ៖ ចុះមានដឹងថាបាញ់ទៅមានមនុស្សស្លាប់អត់?

អ៊ូច ៖ មើលអត់ឃើញ ។

គន្ធី ៖ អត់ដឹង?

អ៊ូច ៖ មើលអត់ឃើញដឹងថាស្លាប់រស់ទេយើងមីលទៅបាញ់វាយើងមិនដឹងត្រូវ ឬមិនត្រូវអីវាមិនទៀងណាព្រោះវានៅពេញមុខពេញមាត់ដូចតែគ្នា ។

គន្ធី ៖ ចុះកាលពេលហ្នឹងមានដូចថាខាងយើង ឬក៏ខាងវៀតណាមហ្នឹងមានចាប់ចំណាត់ខ្មាំងដូចថា គំរាមផ្សេងៗ មានហេតុការណ៍អីផ្សេងក្រៅពីគេបាញ់គ្នាទេ?

អ៊ុច ៖ អត់ៗដែលបានជួបទេប៉ុន្មានរឿងថាសង្គ្រាមដូចថាវៃកាប់សម្លាប់គ្នាអត់ដែលឃើញទេ តែចំពោះសង្គ្រាមគឺបាញ់គ្នាហ្នឹង វាមិនដែលជួបជុំយើងយើងមិនដែលជួបជុំយើងទេណា ។

វិសាល ៖ ចង់ជម្រាបសួរពីរឿងឈ្លើយមានដែលចាប់បានទេអ៊ំ?

អ៊ុច ៖ ឈ្លើយសឹកចាប់បានដែរ ។

គន្ធី ៖ ខាងក្រុមអ៊ំ ឬក៏អ៊ំចាប់បានវៀតណាម?

អ៊ុច ៖ ខាងក្រុមខ្ញុំពួកអាពួកគេដេញមុខណាពួកគេនាំមុខ ។

គន្ធី ៖ ចាប់បានវៀតណាមអ៊ំណែ?

អ៊ុច ៖ ចាប់បានវៀតណាមមិនសូវបេះទុកផង ។

គន្ធី ៖ ប៉ុន្មាននាក់ដែរអ៊ំ?

អ៊ុច ៖ ជួនកាលពីរនាក់បីនាក់ជួនកាលអត់អញ្ចឹងទៅ ឃើញសាប់អញ្ចឹងទៅវាអញ្ចឹង ។

គន្ធី ៖ អ៊ឺ ចាប់បានពីរបីនាក់អញ្ចឹងទៅ យើងធ្វើម៉េចទៀតអ៊ំ?

អ៊ុច ៖ ជយនកាលបញ្ជូនមកក្រោយមក ។

គន្ធី ៖ បញ្ជូនទៅណាវិញ?

អ៊ុច ៖ បញ្ជូនមកកន្លែងអ្នកធំមក ។

គន្ធី ៖ អ្នកធំនៅឯណាវិញ?

អ៊ុច ៖ អ្នកធំនៅក្បោមតាអូរនេះបញ្ជូនមកហ្នឹហើយគេធ្វើម៉េចធ្វើទៅ ។

គន្ធី ៖ វៀតណាមអ៊ំណែ?

អ៊ុច ៖ អ៊ឺ ចាប់វៀតណាមបានបញ្ជូនមកក្រោយ ។

គន្ធី ៖ ក្បោមហ្នឹងជាកន្លែងអីគេអ៊ំ?

អ៊ុច ៖ អាហ្នឹងជាកន្លែងកងពលគេ ។

គន្ធី ៖ កងពលធំ?

អ៊ុច ៖ បាទ!

គន្ធី ៖ ចុះអ៊ំមានដឹងថាគេបញ្ជូនពីក្បោមហ្នឹងទៅណាទៀតទេ?

អ៊ុច ៖ អត់ដឹងព្រោះយើងនៅឯមុខនោះ ។

គន្ធី ៖ ដឹងតែទៅត្រឹមក្បោមហ្នឹង?

អ៊ូច ៖ បាទ!

គន្ធី ៖ ហើយអ៊ឹដូចថាតាមគំនិតអ៊ឹគេបញ្ជូនចំណាត់ខ្មាំងហ្នឹងមកហ្នឹងគេប្រុងឲ្យធ្វើម៉េចវិញទៅអ៊ឹ?

អ៊ូច ៖ អត់ដឹងពេលយើងបញ្ជូនទៅគេទៅមិនដឹងគេធ្វើរបៀបម៉េច យកទៅណាវិញអត់ដឹងទេព្រោះយើងនៅឯមុននោះ ហើយបញ្ជូនមកកន្លែងកងពលនេះ មកយើងម៉េចដឹងព្រោះយើងក្តាប់អត់ជុំ ។

គន្ធី ៖ មានដែលអត់បញ្ជូនមកទេអ៊ឹចំណាត់ខ្មាំងណា?

អ៊ូច ៖ ចំណាត់ខ្មាំងបញ្ជូនមកកន្លែងកងពលហ្នឹងហើយ ដឹងគេយកទៅណាទៀតយើងអត់ដឹង្ស

គន្ធី ៖ ប៉ុន្តែនៅនោះដូចថាក្រៅពីបញ្ជូនអញ្ចឹងអ៊ឹមានធ្វើអីជាមួយចំណាត់ខ្មាំងទៀតទេក្រុមអ៊ឹ?

អ៊ូច ៖ អត់ទេចាប់បានអត់មានប៉ះពាល់ទេ ។

គន្ធី ៖ អត់ប៉ះពាល់ទេអ៊ឹណែ?

អ៊ូច ៖ ចំណាត់ខ្មាំងអត់ឲ្យប៉ះពាល់ទេ ។

គន្ធី ៖ ដឹងតែបញ្ជូនមក?

អ៊ូច ៖ បញ្ជូនមកហ្នឹងបើសិនជាចាប់បានរស់នោះណា ។

គន្ធី ៖ ចុះអ៊ឹអត់ដឹងថាគេធ្វើម៉េចទៀតជាមួយចំណាត់ខ្មាំងហ្នឹងទៀតទេអ៊ឹហ្ន?

អ៊ូច ៖ អត់ដឹងព្រោះកន្លែងអ្នកធំៗអត់ឲ្យយើងចូលជិតទេព្រោះកន្លែងគេនៅដោយឡែក យើងនៅដោយឡែក ។

គន្ធី ៖ ចុះអ៊ឹមានដែលជួបប្រទះប្រជាជនថ្មី ឬក៏នណាដែលគេជាប្រជាជនធម្មតាណា ដែលមានឃើញទៅទល់ដែនដែលជាសមរភូមិកំពង់បាញ់គ្នាហ្នឹងទេ?

អ៊ូច ៖ ក្នុងហ្នឹងមុខសញ្ញាខ្ញុំអត់ដែលបានជួបប្រទះទេនៅតែទព័ហ្នង ។

គន្ធី ៖ អត់ដែលជួបប្រជាជនមូលដ្ឋានក្តីអ្នកថ្មីក្តីអត់ដែលជួបទេ?

អ៊ូច ៖ អត់ទេអត់ដែលជួបទេ ។

គន្ធី ៖ អ៊ឺ អញ្ចឹងអ៊ឹពេលអ៊ឹធ្វើជាទ័ពហ្នឹងមានដែលឃើញមេដឹកនាំណាមួយទៅដូចថា និយាយប្រាប់ណែនាំអ៊ឹ ឬកលើកទឹកចិត្តដូចថាយើងធ្វើជាទាហានអីដែរ?

អ៊ូច ៖ លើកទឹកចិត្តថាធ្វេសគ្រោមជាមួយវៀតណាមត្រូវខំឡើងកុំឲ្យវៀតណាមយកដីតែប៉ុណ្ណឹង ។

គន្ធី ៖ ហើយកាលហ្នឹងមានមេដឹកនាំធំៗដូចថាជាអ្នកតំបន់ ឬក៏អ្នកណាគេអ៊ឹមានដែលដឹងទេ?

អ៊ូច ៖ អ៊ឺ មេកងពលឈ្មោះភា ។

គន្ធី ៖ ភា កងពលឈ្មោះភា?

អ៊ូច ៖ កន្លះពេលពីរហា ។

គន្ធី ៖ គាត់ធំជាងគេអីណែ?

អ៊ូច ៖ ធំជាងគេ ។

គន្ធី ៖ ហើយភាហ្នឹងរាល់ថ្ងៃគាត់នៅឯណាដែរ?

អ៊ូច ៖ មិនដឹងកំណើតនៅឯណាអីណាទេឃើញកាល៧៩ហ្នឹងមិនដឹងទៅណាទៅណីទេ ។

គន្ធី ៖ អត់ដឹងទៅណាទេហ្ន?

អ៊ូច ៖ អត់មិនដឹងទេ ។

គន្ធី ៖ ចុះកាលគាត់គ្រប់គ្រងអីហ្នឹងម៉េចដែរ អីជាផ្ដាច់ការ ឬក៏មានតែការផ្ដលកម្លាំងចិត្តអីយល់យ៉ាងម៉េចដែរចំពោះការគ្រប់គ្រងរបស់គាត់?

អ៊ូច ៖ លើកហេតុផលលើកទឹកចិត្តទ័ពឲ្យប្រយុទ្ធអញ្ចឹងទៅ បើសិនជាមានគ្នាស្លាប់ ឬក៏របួសអីអញ្ចឹងឲ្យជួយយកមកក្រោយ ។

គន្ធី ៖ ចុះគ្នាយើងហ្នឹងដែលវៀតណាមចាប់បានទេ?

អ៊ូច ៖ ចាប់បានដែរទៅវិញទៅមក ។

គន្ធី ៖ ហើយធ្វើម៉េចទៅ?

អ៊ូច ៖ បាត់តែខ្លួនដូចតែគ្នា ។

គន្ធី ៖ អត់ដឹងទេអីណែ?

អ៊ូច ៖ តែបាត់ហើយមិនដែលឃើញមកវិញទេ ។

វិសាល ៖ អញ្ចឹងអីអំបាញ់ម៉េញអីមានប្រសាសន៍ថា ឈ្លើយសឹកហ្នឹងគឺយកមកបាត់ហើយ?

អ៊ូច ៖ បាត់ហើយពេលបញ្ជូនមកមិនដឹងគេយកទៅដាក់គុក ឬក៏យកទៅណាទេយើងអត់ដឹង ។

វិសាល ៖ អីគ្រាន់តែបញ្ជូនមកគឺបាត់ហើយ?

អ៊ូច ៖ បាទ!

គន្ធី ៖ អត់ដែលដឹងថាគេបញ្ជូនទៅភ្នំពេញអីអញ្ចឹងទេ?

អ៊ូច ៖ អត់ដឹង ។

គន្ធី ៖ ហើយមេដឹកនាំក្រៅពីភាហ្នឹងមានអ្នកណាផ្សេងទៀតទេអី?

អ៊ូច ៖ ផន មួយទៀតអាមួយបញ្ជាមួយវេង ។

វិសាល ៖ ផន នៅរស់ទេ?

អ៊ូច ៖ អត់ដឹងដែរមិនដឹងស្រុកកំណើតនៅឯណា បែកមកបេករហូតតាំងពី៧៩មក បែកមកបាត់រហូត ។

គន្ធី ៖ គាត់ជាប្រជាជនមកពីខាងណាវិញភា ហើយនឹងជន ហ្នឹង?

អ៊ូច ៖ ទេមិនដឹងៗប្រវត្តិរូបថានៅឯណាអីឯណា ។

គន្ធី ៖ កងពល៥០២?

អ៊ូច ៖ ២៥០ ។

គន្ធី ៖ ២៥០ អញ្ចឹងអីអត់ដែលមានចំណាត់ថ្នាំងប្រុសស្រីដែលជាអ្នកមូលដ្ឋានអីទេ ជាមនុស្សប្រុសក្តីស្រីក្តីអត់ដែលជួបនៅសមរភូមិទេ?

អ៊ូច ៖ អត់ៗទេ វៀតណាមនៅមុខយើយើងនៅក្រោយវៀតណាមនេះមក អត់ដែលជួបប្រទះ ។

គន្ធី ៖ អីមួយទៀតពេលអីទៅមន្ទីរពេទ្យណា ព្យាបាលហ្នឹងមន្ទីរពេទ្យហ្នឹង អីមានដឹងថាគេបែងចែករវាងអ្នកមូលដ្ឋាន និងអ្នកថ្មីទេ?

អ៊ូច ៖ អត់ គឺថាមន្ទីព្យាបាលទូទៅហ្នង ។

គន្ធី ៖ ទូទៅ មិនមែនសម្រាប់ទាហាន ឬក៏អ្នកមូលដ្ឋានអីទេ?

អ៊ូច ៖ អត់បែងចែកវណ្ណៈទេ មើលទូទៅហ្នង ។

គន្ធី ៖ ចុះភាគច្រើនអ្នកណាចូលមើលដូចថា អ្នកជម្ងឺណាភាគច្រើនជានណាជាទាហានជាអ្នកណាដែរអី?

អ៊ូច ៖ អ្នកមើលហ្នឹងមិនដែលឃើញអ្នកចូលសួរសុខទុរឿងអីទេ អត់ដែលឃើញអ្នកណាចូលមើលលើកទឹកចិត្តអ្នកដេកពេទ្យអីអត់ទេ ។

គន្ធី ៖ តែខ្ញុំចង់អ្នកជមឺណាអី?

អ៊ូច ៖ អ្នកជម្ងឺ?

គន្ធី ៖ ចា៎ អ្នកជម្ងឺភាគច្រើនជាអ្នកអីដែរអីអ្នកចូលមើលជម្ងឺ?

អ៊ូច ៖ អ្នកជម្ងឺចូលព្យាបាលហ្នឹង?

គន្ធី ៖ ចា៎ អ្នកជម្ងឺយើងធមតាដេកពេទ្យដូចអីអញ្ចឹង?

អ៊ូច ៖ ច្រើនតែស្គមៗក្បាលជង្គង់ត្រមោងៗ ។

គន្ធី ៖ ច្រើនអញ្ចេះច្រើនជាអ្នកូលដ្ឋាន ជាទាហាន ឬក៏ជាអ្នកថ្មី ឬក៏ជាអ្នកម៉េចដែរអីចូលទៅមើលជម្ងឺហ្នឹងណា?

អ៊ូច ៈ	អ៊ឺ អាហារហ្នឹងវាមិនសូវមានប៉ុន្មានទេ ព្រោះអាហារមានកន្លែងគេស្នាក់នៅផ្សេងទៀត កន្លែងគេដេកពេទ្យរបួសស៊ីគេមានកន្លែងគេ ហើយកន្លែងយើងរបជាជនដាច់ដោយខ្លួន ។

គន្ធី ៈ	គេបែងចែកប្រជាជនដាច់ដោយខ្លួន?

អ៊ូច ៈ	បាទ!

គន្ធី ៈ	តែប្រជាជនហ្នឹងខ្ញុំចង់បញ្ជាក់អ៊ឹថាជាអ្នកណាដែរដូចថា គាត់ជាថ្នាក់ដឹកនាំខ្ពស់ហ្នឹងមានពេទ្យផ្សេង ឬក៏ពេទ្យហ្នឹងសម្រាប់ព្យាបាលទាំងថ្នាក់តូចថ្នាក់ធំ? ជាកងពលក្តីជាអ្នកមូលដ្ឋាន ឬក៏ជាអ្នកថ្មីអញ្ចឹងណាអ៊ឹ?

អ៊ូច ៈ	ពេទ្យព្យាបាលផ្ទាល់ហ្នុងមិនដែលឃើញអ្នកណាមកបញ្ជាអីទេ ពេទ្យព្យាបាលចល័តទូទៅហ្នុងកន្លែងក្នុងមន្ទីរពេទ្យហ្នឹង ។

គន្ធី ៈ	អ៊ឹខ្ញុំចង់បញ្ជាក់ថាមិនមែនគេបញ្ជាទេខ្ញុំចង់មានន័យថា អ្នកជម្ងឺហ្នឹងជាអ្នកប្រភេទណា ជាអ្នកណាខ្លះដែរអញ្ចឹងណា?

អ៊ូច ៈ	អូ មួយស្រុកគិរីវង្សហ្នឹងគឺ វាមានកន្លែងសម្រាកដូចតាមមួយស្រុកនេះធ្វើកន្លែងស្នាក់មួយល្វែងទៅណា ដេកចល័តមួយស្រុកហ្នឹងដេកមួយកន្លែងទៅរោងពីរល្វែងនឹង ។

គន្ធី ៈ	ចុះប្រជានថ្មីភាគច្រើនចូលទៅមើលហ្នឹងដែរអ៊ឹ?

អ៊ូច ៈ	អ៊ឺ ដូចខ្ញុំនិយាយអញ្ចឹងមិនដឹងអ្នកណាថ្មីអ្នកណាចាស់ទេដូចតែគ្នា ។

គន្ធី ៈ	យើងអត់ស្គាល់?

អ៊ូច ៈ	អត់ស្គាល់ព្រោះប្រជាជនខ្មែរដូចតែគ្នាអត់ដឹងម៉េច បើកាលនៅចល័តហ្នឹងដឹងថាពួកថ្មីហ្នឹងដែងអ៊ឺ អត់ត្រូវចូលទ័ពទេណាក៏នៅតែការហូបចុកដេករួមរស់អីជាមួយគ្នាទាំងអស់ ។

គន្ធី ៈ	ចាំ!

អ៊ូច ៈ	បាទ តែប៉ុណ្ណឹងហើយបើដេកពេទ្យដេកអីដូចគ្នាហ្នឹង បែងចែកវណ្ណៈអីអត់ទេ ។

គន្ធី ៈ	ពេទ្យអីព្យាបាលដូចថាភាគច្រើនអ្នកណាដែលចូលមើលជម្ងឺអ្នកឈឺណា?

អ៊ូច ៈ	ច្រើនអ្នកមូលដ្ឋាន ។

គន្ធី ៈ	មូលដ្ឋានឈឺអីខ្លះដែរអ៊ឹ?

អ៊ូច ៈ	មិនស្គាល់គេទេច្រើនគេយកអ្នកមូលដ្ឋានទៅពេទ្យអ្នកថ្មីគេមិនសូវទេ ។

គន្ធី ៈ	ម៉េចអញ្ចឹងអ៊ឹ?

អ៊ូច ៈ	អត់ដឹងមិនដឹងគេបែកវណ្ណៈយ៉ាងម៉េច ។

គន្ធី ៈ	អ្នកឈឺមូលដ្ឋានគេយកទៅពេទ្យអ៊ឹហ្ន?

អ៊ូច ៖ យកទៅអារអកថ្មីក៏គេយកទៅដែរប៉ុន្តែពេទ្យនៅកន្លែងព្យាបាលហ្នឹងឲ្យតែអ្នកថ្មីអត់ព្យាបាលទេ ។

គន្ធី ៖ ហេតុអីបានអញ្ចឹង?

អ៊ូច ៖ អត់ដឹងវាអត់ចូលចិត្តប្រជាជនថ្មីចាស់ទូទៅអត់អីទេ ។

គន្ធី ៖ ចុះអ៊ំអ៊ី ចំពោះអ៊ំផ្ទាល់ណាអ៊ំមានអារម្មណ៍យ៉ាងម៉េចដែរចំពោះរបបខ្មែរក្រហមដែលអ៊ំរស់នៅរយៈពេលថាតាំងពីគេកៀអ៊ំតាំងពីសម័ លន់ នល់ រហូតមកដល់ពេលបែកណាអ៊ំយល់ថាយ៉ាងម៉េចដែរ?

អ៊ូច ៖ យល់យ៉ាងម៉េចបើយើងរស់នៅក្រោមការគ្រប់គ្រងរបស់សន្តម ត្រូវតាមសន្តមមានការលំបាកច្រើនហើយបើបានមកអញ្ចឹងយើងសប្បាយចិត្ត មានសិទ្ធមានសេរីភាពឃើញទេមានសុភមន្គលយើងចង់ធ្វើយ៉ាងម៉េច ចង់ហូបៗចង់ដើរៗចង់ទៅណាៗបានតាមចិត្តបើមិនរស់ក្នុងសន្តមទេយ៉ប់ហ្នឹង ។ កាលប៉ុន្មានឆ្នាំជួបការលំបាកអត់ដែលដឹងការសប្បាយយ៉ាងម៉េច ។

គន្ធី ៖ ចុះអ៊ំមានដូចថា យល់យ៉ាងម៉េចដែរចំពោះ មានដឹងរឿងតុលាការអីខ្លះទេអ៊ំ?

អ៊ូច ៖ អត់ ។

គន្ធី ៖ តុលាការខ្មែរក្រហមណាអ៊ំ? អត់ដែលដឹងសោះហ្នឹងហ្ន?

អ៊ូច ៖ អត់ដឹង ។

គន្ធី ៖ ដែលឮតាមដូចថា អ៊ី មើលទូរទស្សន៍វិទ្យុអីខាងអ៊ី មានដូចថាគេនិយាយតិចតួចពីរឿងការកាត់ទោសមេដឹកនាំខ្មែរក្រហមអីមានទេ?

អ៊ូច ៖ អញ្ចេះតាំងពីដឹងក្តីមកឮថាគុកទួលស្លែងធំជាងគេនៅភ្នំពេញ គេយកមនុស្សទៅសម្លាប់នៅហ្នឹងច្រើនណាស់ណា ។

គន្ធី ៖ ឮពីពេលណាមក?

អ៊ូច ៖ ឮតាំងពីឆ្នាំ៨០ ៨១ អីហ្នឹងឮថាគុកទួលស្លែងហ្នឹងមានអ្នកធំអ្នកតូចអីគេយកទៅដាក់គុកទួលស្លែងសុទ្ធតែខ្មោច ។

គន្ធី ៖ កាលនៅក្នុងរបបខ្មែរក្រហមហ្នឹងអ៊ំមានដែលដឹងរឿងគុករឿងអីអ៊ំ?

អ៊ូច ៖ អត់ៗដឹង ប៉ិនដល់តែឆ្នាំ៨០ ៧៩បែកមកហើយ៨០នេះឮថាគុកទួលស្លែងសុទ្ធតែអាពតដាក់គុកទាំងអស់ ។

គន្ធី ៖ ចុះអ៊ំមានអារម្មណ៍យ៉ាងម៉េច?

អ៊ូច ៖ មានអារមណ៍យ៉ាងម៉េចបើវាធ្វើបាបខ្មែរយើង ។

គន្ធី : កាលអ៊ំរស់នៅរបបខ្មែរក្រហមអ៊ំអត់ដែលដឹងនេះសោះ ដល់ពេលក្រោយមកអ៊ំដឹងដំណឹងវិញអញ្ចឹងណា?

អ៊ូច : អារម្មណ៍យ៉ាងម៉េចបើខ្មែរយើងវាសម្លាប់អញ្ចឹងហើយ វាសម្លាប់សុទ្ធតែអ្នកចេះដឹងទៀត អាអ្នកល្ងង់ខ្លៅវាអត់សម្លាប់វាយកសុទ្ធតែអ្នកចេះដឹងយកទៅដាក់គុក ។

គន្ធី : កាលហ្នឹងអ៊ំមានដឹងទេកាលសម័យខ្មែរក្រហមអ៊ំមានដឹងខ្លះទេ ថាគេមានសម្លាប់អីអញ្ចឹងណា?

អ៊ូច : អត់ៗដឹង ។

គន្ធី : ដឹងដូចថាមានគេអ្នកផ្សេងៗទៀតមានគេស្លាប់ច្រើនអីអញ្ចឹងណាដឹងទេអ៊ំ?

អ៊ូច : អត់ក្រែងចាស់ៗគេដឹងខ្ញុំអត់ដឹងសោះ ។

គន្ធី : អត់ដឹងទាល់តែសោះ?

អ៊ូច : គេចាស់ៗគេដឹងណា ។

គន្ធី : ចុះប្រជាជនភាគច្រើនដែលនៅក្នុងភូមិអ៊ំកាលអ៊ំនៅ អ៊ី ខ្ញុំសួរបកទៅក្រោយបន្តិចណាអ៊ំ?

អ៊ូច : បាទៗ

គន្ធី : កាលអ៊ំរស់នៅក្នុងភូមិអី
ឬក៏ទៅធ្វើទាហានអីអ៊ំមានឃើញមនុស្សស្លាប់ដូចថាដោយសារជម្ងឺអី ឬក៏ដោយសារធ្វើការហត់អីអញ្ចឹងមានដែលឃើញគេស្លាប់ច្រើនទេ?

អ៊ូច : អញ្ចេះដូចចាស់ៗគាត់ស្លាប់ដោយសារជម្ងឺគាត់អស់ទៅហ្នឹងណា ។

គន្ធី : ចុះក្មេងៗ?

អ៊ូច : ក្មេងហ្នឹងភាគច្រើនកុមារហ្នឹងទៅធ្វើការហួសពេលហួសវេលាអីអញ្ចឹង ពេលខ្លះអត់បាយអត់អីខ្យល់មានស្លាប់អញ្ចឹងដែរណា ។

គន្ធី : មានប្រជាជនគេជម្លៀសមកច្រើនទេនៅភូមិអ៊ំ?

អ៊ូច : ប្រជាជនដូចគ្មានទេហ្នះ ជម្លៀសឲ្យមកតាមភូមិហ្នឹងគ្មានទេភូមិយើង ។

គន្ធី : អត់មានទេហ្ន?

អ៊ូច : បាទ!

គន្ធី : មានប្រជាជនថ្មី?

អ៊ូច : បើប្រជាជនថ្មីមាន ។

គន្ធី : មាន មកពីខាងណាវិញ?

អ៊ូច ៖ អ្នកខ្លះមានស្រុកកំណើតនៅទីក្រុងអញ្ចឹងទៅណា ស្រុកកំណើតយើងមកតាមភូមិអញ្ចឹងមក នៅហ្នឹងវិញមក ។

គន្ធី ៖ ច្រើនទេអ៊ំ?

អ៊ូច ៖ មិនដឹងប៉ុន្មានទេព្រោះខ្ញុំមិនសូវនៅស្រុកផង ។

គន្ធី ៖ អូ ដល់ពេលហ្នឹងអ៊ំមានដឹងថាមនុស្សស្លាប់ច្រើនដោយសារ ដូចថាគាត់អស់កម្លាំងអីទេ?

អ៊ូច ៖ បាទ ព្រោះអញ្ចេះប្រជាជនវាធ្វើការវាច្រើនដែរពេលហួសម៉ោងហ្នឹងវា ជួនកាលខ្លះវាត្រូវជម្ងឺអញ្ចឹងទៅយើងថាអត់បាយទៅក៏បានយើងថាជម្ងឺក៏បាន ព្រោះយើងមើលអត់ឃើញណា ។

គន្ធី ៖ ចាំ ខ្ញុំបកទៅក្រោយវិញខ្ញុំសួររាងនេះបន្តិចអ៊ំទៅមុខក្រោយ ចុះអឺដល់ពេលអ៊ំអត់ដែលដឹងឬក៏ដឹងរឿងតុលាការហ្នឹងដែរធ្លាប់ឮទេអ៊ំ?

អ៊ូច ៖ អត់ៗមានឮរឿងតុលាការអីទេ ។

គន្ធី ៖ រហូតដល់ឥលូវហ្នឹងហ្អ?

អ៊ូច ៖ បាទ ទើបនឹងឆ្នាំ៧៩ហ្នឹងថារឿងមានតុលាការមានអីហ្នឹង ។

គន្ធី ៖ ឥលូវៗហ្នឹងណា?

វិសាល ៖ ចង់ជម្រាបសួរអ៊ំថាប្រហែលជាតាំងពីឆ្នាំ២០០៦មក ដែលឮថាមានតុលាការកើតឡើងនៅភ្នំពេញអីអញ្ចឹងណាដែលឮថាមានទេអ៊ំ?

គន្ធី ៖ តុលាការអន្តរជាតិអីណាអ៊ំ?

អ៊ូច ៖ អត់អត់ដែល ។

វិសាល ៖ អត់ដែលឮសោះ?

អ៊ូច ៖ មើលតាមស៊ីឌីតាមប៉ុស្តហ្នឹង ដឹងតាមគេផ្សាយសាច់រឿងដឹងតែចំពោះមិនដឹងទេ ។

វិសាល ៖ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅភ្នំពេញនេះអត់ដែលឮទេ?

អ៊ំស្រី ៖ ទើបបើកទូរទស្សន៍មើលឃើញគេផ្សាយឥលូវៗហ្នឹង ។

គន្ធី ៖ ពីអង្កាល ឥលូវៗហ្នឹងពីអង្កាល?

អ៊ំស្រី ៖ ឥលូវៗហ្នឹងប៉ុន្មានឆ្នាំ?

អ៊ំស្រី ៖ ផ្សព្វផ្សាយយូដែរហើយដែលថាកាត់ទោសប៉ុលពតអី គេមិនប្រកាស ។

វិសាល ៖ អូអញ្ចឹងបានដឹងខ្លះដែរ ដឹងប៉ុណ្ណាទៅអ៊ំដឹងយ៉ាងម៉េចខ្លះទៅអាចជួយប្រាប់ខ្ញុំបានទេ?

អ៊ូច ៖ ដឹងដែរវាយូភ្លេចហើយតាមរ៉ាត់យ៉ូនោះ ។

អ៊ុំស្រី : ដឹងៗ ពេលស្តាប់ហ្នឹងស្តាប់ហើយភ្លេចអស់ហើយ ។

អ៊ូច : ភ្លេចការចងចាំ ។

អ៊ុំស្រី : មិនភ្លេចការចងចាំទេវាដូចថាមិនយកចិត្តទុកដាក់វាភ្លេច ។

វិសាល : បាទ តាមការប្រកាសព័ត៌មានជាក់ស្តែងគឺគេមានបង្កើតតុលាការមួយចំរុះណាអ៊ំណា គឺមានខាងអង្គការសហប្រជាជាតិផង ហើយនិងមានខាងរដ្ឋាភិបាលយើងផងចូលរួមសហការណ៍គ្នា ។

គន្ធី : អូ ហើយពេលអញ្ចឹងអ៊ុំខ្ញុំចង់បើកវង់ក្រចកសួរដូចថា ក្រុមអ៊ុំមានបញ្ជូនក្រៅពីទៅវ៉ៃជាមួយវៀតណាមអត់មានទៅណាទៅណីផ្សេងទៀតដូចថា គេបញ្ជូនអ៊ុំទៅណាតំបន់ណាខេត្តណាទៀតទេ?

អ៊ូច : អត់ទេ ពួកខ្ញុំនៅឈរជើងខាងនៅនេះហ្នងខាងព្រំដែនយើងអត់មានទៅណាទៀតទេ នៅហ្នឹងហ្នង ។

វិសាល : អូ អញ្ចឹងខ្ញុំសូបបន្តរឿងតុលាការបន្តិចទៀតអ៊ំណា បាទ តុលាការហ្នឹងគេបង្កើតឡើងក្រោមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិហើយបើតាមអ្វីដែលគេប្រកាសហ្នឹងគឺបង្កើតឡើងដើម្បីកាត់ទោសពួកមេដឹកនាំខ្មែរក្រហម អ្នកទទួលខុសត្រូវខ្ពស់បំផុតអ៊ំណា គឺមេធំៗនៅខាងលើនោះ ហើយបំណងគេបង្កើតឡើងគឺដើម្បីរកយុត្តិធម៌ដល់ប្រជាពលរដ្ឋខ្មែរណាអ៊ំណា ព្រោះមេធំៗហ្នឹងហើយ ដែលជាអ្នកចេញនយោបាយអញ្ចឹងណាអ៊ំណា បាទៗ ។

អ៊ូច : បាទ!

វិសាល : ហើយមានបានឮអញ្ចឹងទេអ៊ំ?

អ៊ូច : ដឹងផ្សាយដែរ ។

វិសាល : អញ្ចឹងមើលទៅបើតាមគំនិតអ៊ំពេញចិត្ត និងតុលាការហ្នឹងទេ ពេលមានតុលាការរកយុត្តិធម៌អញ្ចឹង?

អ៊ូច : ហ្នឹងបើតុលាការកាត់ទោសដើម្បីរកយុត្តិធម៌ខ្ញុំពេញចិត្ត ។

វិសាល : ពេញចិត្ត រីករាយតែម្តងអ៊ំណែ?

អ៊ំ : បាទ ពេញចិត្តតែម្តងព្រោះកាលសង្គមវានេះធ្វើបាបប្រជាជនយើងសម្បើមណាស់ ។

វិសាល : បាទៗ ។

អ៊ូច : ធ្វើបាបប្រជាជនប្រើមិនដឹងថ្ងៃដឹងយប់អីទេ បើបានធ្វើតុលាការកាត់ទោសខ្ញុំអរណាស់ ។

វិសាល : ពេញចិត្ត?

អ៊ួច : ពេញចិត្តណាស់ ។

វិសាល : ចង់បានយុត្តិធម៌អីទេអ៊ំ?

អ៊ួច : ទាមទារកយុត្តិធម៌ដែរព្រោះពួកវានេះពួកវាធ្វើបាបប្រជាជន បាទ ធ្វើបាបប្រជាជនយើងកាត់កាត់ទោសអញ្ចឹងខ្ញុំសប្បាយពេញចិត្ត ។

វិសាល : ដែលនិយាយរឿងរ៉ាវឈឺចាប់ហ្នឹងប្រាប់កូនចៅ ឬក៏សាច់ញាតិជិតខាងក្មេងៗ កូនៗអ៊ំទេ?

អ៊ួច : ប្រាប់កូនដែរថា កូនអ៊ុយជំនាន់ ប៉ុល ពត ជួបការលំបាកច្រើនណាស់ឪពុកម្តាយធ្វើការ ។

វិសាល : អ៊ំជាទាហានដេកនៅត្រង់សេ?

អ៊ួច : បាទ ទោះខ្យល់ភ្លៀងយ៉ាងម៉េចខំធ្វើការមិនថាក្តៅថាត្រជាក់ភ្លៀងទេ ហើយសង្គមនេះយើងដើម្បីថាចង់ធ្វើអ្វីក៏បានមិនចង់ធ្វើក៏បាន ហើយយើងមានសិទ្ធសេរីភាពដើរហើទៅណាឲ្យតែមានសំភារៈ ឬមានលុយកាក់អីដើរទៅណាក៏បានដែរ ជៀសវាងកុំឲ្យខ្មែរក្រហមចូលមកទៀត ។

វិសាល : បាទ! គាត់ជឿទេអ៊ំនិយាយអញ្ចឹងគាត់ជឿទេ សូមទោសអ៊ំ?

គន្ធី : គាត់ជឿទេក្មេងៗកូនអ៊ំហ្នឹងជឿទេ?

អ៊ួច : អូ ជឿវាថាអូជួបការលំបាកមែនកាលអាពតហ្នឹង ដល់តែគេលេងរឿងអាពតហ្នឹងឲ្យមើលដើរតួឃើញទេកូនឯងជួបការលំបាកយ៉ាងម៉េចនេះ ជៀសវាងកុំឲ្យអាហ្នឹងមកទៀតណាកូនថ្ងៃអនាគតទៅ កូនឯងមើលនេះគេលេងសាច់រឿងឲ្យមើលតាមហ្នឹងអាដឹកនាំប្រជាជនទៅវ៉ៃចោលយ៉ាងម៉េច អីយ៉ាងម៉េចឃើញទេមានកាំភ្លើងមានអីតាមផ្លូវយកទៅវ៉ៃចោលឈាមរនេះរនៀលអស់ហើយ ឲ្យវាមើលសាច់រឿងឃើញ ។

គន្ធី : អ៊ំពេលឃើញសាច់រឿងហ្នឹង ឃើញគេលេងដូចអ្វីដែលក្នុងហេតុការណ៍អ៊ំទេ ឬមួយក៏អ៊ំគិតម៉េចដែរ?

អ៊ួច : រឿងអស់ហ្នឹងបើហេតុការមិនដាក់ស្តែងធ្វើបានតែបើដាក់ស្តែងធ្វើមិនបានទេ តាំងពីសម្លៀកបំពាក់តាំងពីមួកតាំងពីឬកពាររបស់វាឃើញទេ សម្ពុតគម្រាមកំហែងប្រជាជនយើងតាមអស់ហ្នឹង ។

វិសាល : អូ ខ្ញុំសូមអរគុណអ៊ំច្រើនអ៊ំណា ដែលបានផ្តល់សាច់រឿងអនុញ្ញាតិឲ្យពួកខ្ញុំសូមសួរសាច់រឿងចំពោះអ៊ីដែលកើតមាននៅក្នុងសម័យខ្មែរក្រហម ហើយអរគុណអ៊ំច្រើនដែលចំណាយពេលវេលា ។

អ៊ូច ៈ បាទៗ ។

វិសាល ៈ អរគុណច្រើនណាអ៊ំណា សូមជំរាបលា ។

**-ចប់-**